# មុខវិជ្ជា៖
# វេលក និងអរូបនិច

## កញ្ចប់សមត្ថភាពទី ១
## ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ

## ពណ៌នាអំពីមុខវិជ្ជា៖

ក្នុងមុខវិជ្ជានេះអ្នកសិក្សានឹងបានរៀនពីមូលដ្ឋានគ្រឹះនៃមេកានិចសម្រាប់ការអនុវត្តន៍ទៅលើបាតុភូតរលក បាតុភូតពាក់ព័ន្ធទៅនឹងរលក ប្រភេទនៃរលក និងការអនុវត្តន៍គោលគំនិតរលកក្នុងទ្រឹស្តីផ្សេងៗក្នុងរូបវិទ្យា។

## លទ្ធផលសិក្សារំពឹងទុក៖

- ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖

**លទ្ធផលសិក្សារំពឹងទុកទី១៖** អនុវត្ត (Apply) នូវមេរៀនលេកមេកានិចដែលមានទំនើបកម្មឌីជីថលក្នុងវិធីសាស្ត្របង្រៀននិងមូលដ្ឋានគ្រឹះការយល់ពីគំនិតក្នុងលេកមេកានិចសមស្របក្នុងការបង្រៀនថ្នាក់មធ្យមសិក្សា

**លទ្ធផលសិក្សារំពឹងទុកទី២៖** ដោះស្រាយ (Solve) លំហាត់ពាក់ព័ន្ធនឹងលេកមេកានិច ដោយមានការចងក្រងនូវឯកសារដោះស្រាយលំហាត់ក្នុងមេរៀននីមួយៗតាមរយៈកិច្ចការក្រុម

**លទ្ធផលសិក្សារំពឹងទុកទី៣៖** បកស្រាយ (Interpret) នូវដំណោះស្រាយបញ្ហាលេកមេកានិច ដោយផ្អែកលើគោលការណ៍ ច្បាប់និងទ្រឹស្តីវិទ្យាសាស្ត្ររូបវិទ្យា ពីកម្រិតប្រធានបទត្រមោចទៅកម្រិតអន្តរប្រធានបទ

**លទ្ធផលសិក្សារំពឹងទុកទី៤៖** សហការណ៍គ្នា (Cooperate) ក្នុងការស្វែងយល់និងដោះស្រាយបញ្ហាក្នុងក្រុមដោយផ្អែកលើផ្នត់គំនិតយកវិធីសាស្ត្រនិងយន្តការជាគោល

## របាយតម្លៃសិក្សា

- ដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់ការសិក្សាមុខវិជ្ជានេះ អ្នកសិក្សាត្រូវ

    ១. វត្តមានចូលសិក្សា ១០%

    ២. ការចូលរួមសកម្មភាពសិក្សា ២០%

    ៣. ការវាយតម្លៃកំឡុងពេលសិក្សា ៣០%

    ៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

# អារម្ភកថា

វិស័យអប់រំ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាជាវិស័យអាទិភាព និងត្រូវបានធ្វើកំណែទម្រង់ជាប្រចាំ ឆ្ពោះទៅលើកកម្ពស់គុណភាពនៃការសិក្សានៅគ្រប់កម្រិត។ ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងពិនិត្យឡើងវិញកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងជំរុញកំណែទម្រង់សាលារៀននៅគ្រប់កម្រិត ដើម្បីធានាថាសាលារៀនមានដំណើរការប្រកបដោយប្រសិទ្ធភាពសម្រាប់ការសិក្សារៀនសូត្ររបស់សិស្ស និងផ្តល់ដល់សិស្សនូវវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា ឆ្លើយតបបានទៅតាមតម្រូវការទីផ្សារការងារ និងចូលរួមចំណែកពេញលេញក្នុងការអភិវឌ្ឍសហគមន៍ និងប្រទេសជាតិ ឈានឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០ ។

ជាផ្នែកមួយនៃកំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន ឆ្ពោះទៅលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនតាមរយៈគម្រោងកែលម្អការអប់រំចំណេះទូទៅ ក្រសួងបានរៀបចំ "ក្របខណ្ឌកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលបរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេសទាំង ៦ (អក្សរសាស្ត្រខ្មែរ, គណិតវិទ្យា, គីមីវិទ្យា, ជីវវិទ្យា, រូបវិទ្យា, ប្រវត្តិវិទ្យា) ដើម្បីប្រើប្រាស់ក្នុងកម្មវិធីក្រឹតការគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅតាមសាលារៀនចំណេះទូទៅ។ ក្របខណ្ឌកម្មវិធីសិក្សានេះជាឯកសាររស់ ដែលនឹងអាចមានការកែសម្រួលទៅតាមស្ថានភាពជាក់ស្តែង ជាពិសេសនៅដំណាក់កាលអន្តរកាលនៃការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន។

ក្រសួងមានជំនឿយ៉ាងមុតមាំ លើប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលនេះ ដែលនឹងនាំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀននៅគ្រប់ភូមិសិក្សា សម្រេចបានគោលដៅអប់រំ ដែលនឹងចូលរួមចំណែកក្នុងការសម្រេចបានចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរដ៏ស្មោះចំពោះ ឯកឧត្តមបណ្ឌិតសភាចារ្យនាយកគម្រោង និងក្រុមការងារគម្រោងកែលម្អការអប់រំចំណេះទូទៅ ជាពិសេសក្រុមការងារនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលបានខិតខំផលិតឯកសារក្របខណ្ឌកម្មវិធីសិក្សានេះឡើង សម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាលក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ។

ថ្ងៃ ចន្ទ ៧រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# គណៈកម្មការ

## ១. គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហង់ជួន ណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា |
| ២. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣. ឯកឧត្តមបណ្ឌិត | **ជេត ជាលី** | សាកលវិទ្យាធិការសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោកបណ្ឌិត | **ឈុន ហុក** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោក | **ប៉ាល់ ដេល** | សាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោកបណ្ឌិត | **សំអោ អង្គារតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ៧. លោក | **ព្រីង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |

## ២. គណៈកម្មការនិពន្ធ រៀបរៀង និងចងក្រង

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សុខ សុត្រា** | ព្រឹទ្ធបុរសមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ២. លោក | **មាក ភារម៉េរ៉ាន** | ព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៣. លោកបណ្ឌិត | **ជ័យ ចាន់រឿន** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៤. លោកបណ្ឌិត | **ម៉ម សុជាតិ** | ព្រឹទ្ធបុរសរងមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៥. លោក | **សុត វិសាល** | ប្រធានដេប៉ាតឺម៉ង់សិក្សាអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៦. លោកបណ្ឌិត | **ឃុន គីមលាង** | ប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៧. លោកស្រីបណ្ឌិត | **ស៊ូ កល្យាណ** | អនុប្រធានដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៨. លោក | **ហង់ ស៊ីម** | សាស្ត្រាចារ្យដេប៉ាតឺម៉ង់រូបវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៩. លោក | **ដួង ប៉េងអាន** | អ្នកសម្របសម្រួលកម្មវិធីមធ្យមសិក្សា មហាវិទ្យាល័យអប់រំ |
| ១០. កញ្ញា | **ហុង ឡៃហៀក** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១១. លោក | **សើ ពន្លក** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

## ៣. គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

| | | |
|---|---|---|
| ១. លោកបណ្ឌិត | **សំអោ អង្គារតន៍** | អគ្គនាយករង អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ |
| ២. លោក | **ព្រីង មរកត** | ប្រធាននាយកដ្ឋានមធ្យមសិក្សា |
| ៣. លោក | **ង៉ោ ប៉េងឡុង** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ |
| ៤. ឯកឧត្តមបណ្ឌិត | **សិត សេង** | នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ |
| ៥. លោកបណ្ឌិត | **ឈុក ច័ន្ទនាយ៉ា** | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ |
| ៦. លោក | **កែវ សារ៉ាត់** | ទីប្រឹក្សាបច្ចេកទេសគម្រោងកែលម្អការអប់រំចំណេះទូទៅ |

## ៤. ការិយាល័យ

| | | |
|---|---|---|
| ១. លោក | **ម៉ៅ ម៉ារ៉ាឌី** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ២. លោក | **ឧន សំណាង** | បុគ្គលិកមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

## លទ្ធផលសិក្សារំពឹងទុក

ការសិក្សាក្នុងកម្មវិធីនេះគឺផ្ដោតលើប្រតិបត្តិជាក់ស្ដែងរបស់អ្នកសិក្សាដែលអនុវត្តផ្ទាល់នៅសាលារៀន។ ទាំងអ្នកសិក្សា និងសិស្ស (ដែលអ្នកសិក្សានឹងធ្វើការជាមួយផ្ទាល់) ចាំបាច់មាន (១) បំណិនចិត្តសង្គម (២) បំណិនពុទ្ធិ និង (៣) បំណិនបច្ចេកទេស ជាមូលដ្ឋាន (ដូចក្នុងរូបទី១)។ កញ្ចប់សមត្ថភាពទាំងបីខាងដើមនឹងជួយឱ្យអ្នកសិក្សា អភិវឌ្ឍបំណិនចិត្តសង្គម បំណិនពុទ្ធិ និងពង្រឹងសមត្ថភាពផ្នែក (ក)ការសម្រេចចិត្ត ទំនាក់-ទំនង សេចក្ដីអំណត់ ទឹកចិត្តអាណិតអាសូរ និងការគ្រប់គ្រងខ្លួនឯង ថែមទាំងអាចអនុវត្តការបង្រៀនមុខវិជ្ជា ឯកទេសរូបវិទ្យាប្រកបដោយវិជ្ជាជីវៈ និងនវានុវត្តន៍ដោយប្រើប្រាស់ឧត្តមានុវត្តន៍ផ្សេងៗ (ខ) ការដោះស្រាយបញ្ហា និង ការរៀបចំនិងការចាត់ចែង (គ) បច្ចេកទេសកម្រិតមធ្យម និងកម្រិតខ្ពស់។




*រូបភាពទី១*
*ប្រភព៖ WDR2018 (p.103)*

ដោយឡែក សម្រាប់អ្នកសិក្សាកម្មវិធីនេះផ្ទាល់ នឹងទទួលបាន៖

**(១) ចំណេះដឹងឯកទេសរូបវិទ្យាកម្រិតបរិញ្ញាបត្រ**

- ❖ អគ្គិសនីទូទៅ
- ❖ មេកានិច
- ❖ ទែម៉ូឌីណាមិច
- ❖ រលក និងអុបទិច
- ❖ ពិសោធន៍រូបវិទ្យា
- ❖ ចិត្តសង្គម ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង
- ❖ សន្លឹកកិច្ចការស្វ័យសិក្សានៅមធ្យមសិក្សា
- ❖ ការសរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេសរូបវិទ្យា

**(២) ចំណេះដឹងវិធីគរុកោសល្យ សាស្ត្របង្រៀន និងការអប់រំរូបវិទ្យាកម្រិតមធ្យមសិក្សា**

- ❖ វិធីសាស្ត្របង្រៀន
- ❖ វិធីសាស្ត្រវង្វាយតម្លៃ
- ❖ ការស្រាវជ្រាវប្រតិបត្តិ
- ❖ ប្រឹក្សាគរុកោសល្យ
- ❖ បំណិនឌីជីថលសម្រាប់ការអប់រំ

**(៣) ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង**

- ❖ អនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន
- ❖ ការអនុវត្តកម្មវិធីស្វ័យសិក្សារូបវិទ្យា ពីទីថ្នាក់៧-ទី១២
- ❖ របាយការណ៍នៃការអនុវត្តស្តង់ដា នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន

លទ្ធផលសិក្សារំពឹងទុកសម្រាប់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ ត្រូវបានកំណត់ដូចខាងក្រោម៖

***វិជ្ជាសម្បទា***

PLO1- ពន្យល់អំពីទ្រឹស្តី និងគោលការណ៍នៃការអប់រំក្នុងបរិបទសកលលោក និងបរិបទ ប្រទេសដើម្បីឆ្លុះបញ្ចាំងទៅនឹងការអនុវត្តជាក់ស្តែងនៃការបង្រៀន។

PLO2- បកស្រាយអំពីដំណើរការអនុវត្តកិច្ចការសម្រាប់ការបង្វឹកលើការរៀបចំកម្មវិធីសិក្សា និងការបង្រៀនរូបវិទ្យាប្រកបដោយប្រសិទ្ធភាព។

***បំណិនសម្បទា***

PLO3- អនុវត្តបំណិនចិត្តសង្គម និងបច្ចេកវិទ្យាឌីជីថលសម្រាប់បង្កើនការប្រាស្រ័យទាក់ទងគ្នាក្នុងការងារ និងជីវភាពប្រកបដោយវិជ្ជាជីវៈ និងដោះស្រាយបញ្ហាប្រកបដោយភាពច្នៃ ប្រឌិត និងការទទួលខុសត្រូវ។

PLO4- បង្កើតគន្លឹះ និងទម្រង់សម្រាប់ដឹកនាំ និងគ្រប់គ្រងការបង្រៀនដោយផ្តោតលើផលសម្រេចនៃការសិក្សារបស់សិស្សឆ្ពោះទៅកែស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងនិរន្តភាពសាលារៀនតាមរយៈការសិក្សា ការអនុវត្តជាក់ស្តែង និងការស្រាវជ្រាវ។

PLO5- អនុវត្តការងារអភិវឌ្ឍកម្មវិធីសិក្សា ការរៀននិងការបង្រៀនរូបវិទ្យា និងការសិក្សាបែបគម្រោងភ្ជាប់នឹងបំណិនរកចំណូលសម្រាប់សាលារៀនប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

***ចរិយាសម្បទា***

PLO6- អភិវឌ្ឍឥរិយាបថវិជ្ជមាន និងវប្បធម៌រៀនពេញមួយជីវិតសម្រាប់បំពេញការងារ និងទាក់ទងជាមួយអ្នកដទៃប្រកបដោយគុណតម្លៃ មនុស្សធម៌ សាមគ្គីភាព និងការចែករំលែកគ្នា។

PLO7- បង្កើត/បង្ហាញការដឹកនាំបណ្តាញសម្រាប់កសាងភ្នាក់ងារពង្រីកឧត្តមានុវត្តន៍សម្រាប់ការរៀន និងការបង្រៀន។

សម្គាល់៖ Program Learning Outcome (PLO) លទ្ធផលសិក្សាកម្មវិធីអប់រំ

## កញ្ចប់សមត្ថភាព និង រចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀននេះ តម្រូវឱ្យអ្នកសិក្សាសិក្សាចំនួន ៦៣ ក្រេឌីតដែលមានរយៈពេលចន្លោះពី ១២ ទៅ ១៨ខែ។ ការសិក្សានិងធ្វើឡើងតាមរយៈការរៀនពីចម្ងាយ (ភាគច្រើនចន្លោះពី ៦០% ទៅ ៧០%) និងសិក្សាផ្ទាល់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិង សាលាហាត់ការ (ភាគតិចចន្លោះពី ៤០% ទៅ ៣០%)។ ការសិក្សាផ្តោតលើបណ្តុំមុខវិជ្ជា (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៣៦ ក្រេឌីត) (២)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សា (១២ (+៣) ក្រេឌីត) (៣) ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង(១២ ក្រេឌីត)។ បន្ថែមពីលើនេះទៀតអ្នកសិក្សាត្រូវអនុវត្តខ្លឹមសារមេរៀនដែលបានសិក្សាក្នុងកម្មវិធីនៅសាលាសាមីផ្ទាល់តែម្តងដោយមានការណែនាំពីគ្រូបង្វឹក ប្រឹក្សាគរុកោសល្យ គ្រូបង្រៀននៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងមន្ត្រីអប់រំមកពីនាយកដ្ឋានជំនាញផ្សេងៗរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលមានបទពិសោធន៍អនុវត្តជាក់ស្តែងកន្លងមក ។

| បណ្តុំមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ៣៦ |
| (២)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សា (២០%) | ១២ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង (២០%) | ១២ |
| សរុប | ៦០ (+៣) |

***សម្គាល់៖*** *សម្រាប់កញ្ចប់សមត្ថភាពចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និងការអប់រំមធ្យមសិក្សាបានបន្ថែមមុខវិជ្ជាបំណិនឌីជីថលសម្រាប់ការអប់រំចំនួន ៣ក្រេឌីត*

## លក្ខណៈទូទៅនៃមុខវិជ្ជាសិក្សា

មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រអប់រំនេះនឹងជួយឱ្យអ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោម ដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យអ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| បណ្តុំមុខវិជ្ជា | មុខវិជ្ជាសិក្សា | ក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | អគ្គិសនីទូទៅ | ៣ |
| | មេកានិច | ៣ |
| | ទែម៉ូឌីណាមិច | ៣ |
| | រលក និងអុបទិច | ៣ |
| | ពិសោធន៍រូបវិទ្យា | ៣ |
| | ការអនុវត្តសន្លឹកកិច្ចការរូបវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត១ (ចងចាំ) | ៣ |
| | ការអនុវត្តសន្លឹកកិច្ចការរូបវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត២ (យល់ដឹង) | ៣ |
| | សន្លឹកកិច្ចការរូបវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត៣ (ហ្វឹកហាត់) | ៣ |
| | សន្លឹកកិច្ចការរូបវិទ្យាសម្រាប់សិស្សស្វ័យសិក្សាកម្រិត៤ (វាយតម្លៃ) | ៣ |
| | ការសរសេរ និងការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស | ៩ |
| (៣)ចំណេះដឹងគរុកោសល្យ វិធីសាស្ត្របង្រៀន និង | វិធីសាស្ត្របង្រៀន បត់បែនតាមសមត្ថភាពសិស្ស និងទស្សនទានអប់រំថ្មីៗ | ៣ |
| | ប្រឹក្សា និងហ្វឹកហ្វឺនគរុសល្យលើយុទ្ធសាស្ត្រសហគមន៍សាលារៀន | ៣ |

| | | |
|---|---|---|
| ការអប់រំមធ្យមសិក្សា (២០%) | មូលដ្ឋានគ្រឹះវង្វាយតម្លៃអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះនៃការស្រាវជ្រាវប្រតិបត្តិ | ៣ |
| | បំណិនឌីជីថលសម្រាប់ការអប់រំ* | ៣ |
| (៤)ហ្វឹកហាត់កម្មសិក្សាគរុកោសល្យ និងការអនុវត្តជាក់ស្តែង (២០%) | ការអនុវត្ត ស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀន (ស្តង់ដាទី១) | ៣ |
| | ការអនុវត្ត ស្តង់ដានៃយុទ្ធសាស្ត្រសហគមន៍សាលារៀន (ស្តង់ដាទី២) | ៦ |
| | របាយការណ៍និងការការពារស្តីពីការអនុវត្តស្តង់ដាយុទ្ធសាស្ត្រសហគមន៍សាលារៀន | ៣ |
| សរុប | | ៦៣ |

## លំហូរបង្រៀន និងរៀន

**លំហូរបង្រៀននិងរៀន ១មេរៀន ឬកិច្ចការមួយ រួមជាមួយបំណិនមួយ និងចរិយាមួយ**




## ការវាយតម្លៃលើការសិក្សា

ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេរ ឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

### ៦.៤.១ គោលការណ៍វាយតម្លៃ

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់អ្នកសិក្សាមានដូចតទៅ៖

១) អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ

២) ក្នុងករណីដែលអ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ

៣) អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់

៤) អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗ តាមការកំណត់ក្នុងកម្មវិធីសិក្សា

៥) អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្នូលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្ដោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍ និង

៦) អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។

## ការផ្ដល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពារឯកសារជំនួយស្មារតីមុខវិជ្ជាឯកទេស។ ពិន្ទុដែលជាប់ត្រូវចាប់ផ្ដើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average–GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point–P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value–C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា «ពិន្ទុជានិទ្ទេស» និង «ពិន្ទុជាតម្លៃលេខ» ដូចដែលពិពណ៌នាខាងក្រោម៖

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## ៦.៥ គោលការណ៍ប្រតិបត្តិ

ដើម្បីធានានូវការផ្ដល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្តិសិទ្ធិ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា អ្នកសិក្សាម្នាក់ៗត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោមៈ

### ៦.៥.១ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យ ចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្តភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងគ្រឹះស្ថានសិក្សា និងក្រៅគ្រឹះស្ថានសិក្សា។ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់អ្នកសិក្សាម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់អ្នកសិក្សាម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

### ៦.៥.២ ការក្លែងបន្លំឯកសារ

អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ អ្នកសិក្សាត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរដែលអាចឈានដល់ការបញ្ឈប់បុគ្គលដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ ត្រូវសម្រេចឱ្យធ្លាក់ជាស្ថាពរ បើអ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីអ្នកសិក្សាដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

### ៦.៥.៣ ឯកសារជំនួយស្មារតី/របាយការណ៍/កិច្ចការស្រាវជ្រាវ

អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិត ជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សា បច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួលពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សម្គាល់ៈ** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តជាក់ស្តែងឱ្យឆ្លើយតបទៅនឹង វឌ្ឍនភាពការរៀននិងបង្រៀន សមត្ថភាពរៀននិងការអនុវត្តជាក់ស្តែង និង ស្ថានភាពរៀននិងបង្រៀនជាក់ស្តែង ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ។

# រលក និង អុបទិច












2024

## រលក និង អុបទិច ក្នុងសៀវភៅពុម្ព

Grade 08

| | |
|---|---|
| ៦ | សូរ |
| ៦.១ | ការបង្កើតសូរ |
| ៦.២ | ទំនួលសូរ |
| ៦.៣ | ចំណាងផ្លាតនៃសូរខ្ទរ |

Grade 09

| | |
|---|---|
| ៥ | អុបទិច |
| ៥.១ | ដំណាលត្រង់នៃពន្លឺ |
| ៥.២ | ចំណាំងផ្លាតនៃពន្លឺ |
| ៥.៣ | ចំណាំងបែរនៃពន្លឺ |
| ៥.៤ | ឡង់ទី |

Grade 10

| | |
|---|---|
| ៤ | អុបទិច |
| ៤.១ | ធម្មជាតិនិងដំណាលនៃពន្លឺ |
| ៤.២ | ឡង់ទី |

Grade 11

| | |
|---|---|
| ៣ | រលក |
| ៣.១ | ចលនាខួប |
| ៣.២ | រលក |
| ៣.៣ | សូរ |

Grade 12

| | |
|---|---|
| ២ | រលក |
| ២.១ | គោលការណ៍តម្រួតនៃរលក និងរលកជញ្ជ្រាំ |
| ២.២ | អាំងទែផេរ៉ង់ និងឌីប្រាក់ស្យុង |

# រំលឹក៖ មុំពិសេស

រំលឹក៖ មុំពិសេស

| | $0$ | $\frac{\pi}{6}$ | $\frac{\pi}{4}$ | $\frac{\pi}{3}$ | $\frac{\pi}{2}$ |
|---|---|---|---|---|---|
| $\theta$ | $0°$ | $30°$ | $45°$ | $60°$ | $90°$ |
| $\sin\theta$ | $0$ | $\frac{1}{2}$ | $\frac{\sqrt{2}}{2}$ | $\frac{\sqrt{3}}{2}$ | $1$ |
| $\cos\theta$ | $1$ | $\frac{\sqrt{3}}{2}$ | $\frac{\sqrt{2}}{2}$ | $\frac{1}{2}$ | $0$ |
| $\tan\theta$ | $0$ | $\frac{\sqrt{3}}{3}$ | $1$ | $\sqrt{3}$ | undef. |

# មេរៀនទី រលកមេកានិច



# មេរៀនទី១ រលកមេកានិច (រំលឹក៖ ទំនាក់ទំនង ផ្សេងៗ)

រំលឹក៖ ទំនាក់ទំនង ផ្សេងៗ

sin cos tan

a. $\theta \rightarrow \frac{\pi}{2} - \theta$

b. $\theta \rightarrow \frac{\pi}{2} + \theta$

c. $\theta \rightarrow \pi - \theta$

d. $\theta \rightarrow \pi + \theta$

e. $\theta \rightarrow 2\pi - \theta$

$$\sin\left(\frac{\pi}{2} - \theta\right) = \cos\theta$$

$$\cos\left(\frac{\pi}{2} - \theta\right) = \sin\theta$$

$$\tan\left(\frac{\pi}{2} - \theta\right) = \cot\theta$$




កិច្ចការ1. សូមសរសេរទំនាក់ទំនង sin, cos, tan ករណីមុំផ្សេងៗ គឺ b, c, d, e។

# មេរៀនទី១ រលកមេកានិច (រំលឹក ចលនាខួប)

ចលនាខួប ជាចលនាដែលកើតឡើងដដែលៗ ដូចគ្នាបេះបិទក្នុងរយៈពេលស្មើៗគ្នា។

1. ចលនាវង់ស្មើ ($|\vec{v}| =$ ថេរ និង គន្លងរាងជារង្វង់)

-ល្បឿនមុំ $\omega = \frac{\Delta\theta}{\Delta t} =$ ថេរ $(rad/s)$

-វ៉ិចទ័រទីតាំង $\vec{r}(t) = x(t)\hat{\imath} + y(t)\hat{\jmath}$

ដែល $x(t) = x_{\max}\cos(\omega t + \phi)$

និង $y(t) = y_{\max}\sin(\omega t + \phi)$

ហើយ

$\theta = \omega t + \phi$ ហៅថាផាស (rad)

$\phi$ ហៅថាផាសដើម (rad)

$x_{\max} = y_{\max} = A$ ហៅថាអំព្លីទុត




-ខួប $T = \frac{2\pi}{\omega}$ (s)

-ប្រេកង់ $f = \frac{1}{T} = \frac{\omega}{2\pi}$ ($s^{-1}$ ឬ Hz ឬ ចំនួនជុំក្នុងមួយវិនាទី)

-កិច្ចការ2៖ រកវ៉ិចទ័រល្បឿន? រកវ៉ិចទ័រសំទុះ? ម៉ូឌុលវាទាំងពីរ?

# មេរៀនទី១ រលកមេកានិច (រំលឹក ចលនាខួប)

## 2. ចលនាអាកម៉ូនិចងាយ (Simple Harmonic Motion)




កើតឡើងនៅពេលកម្លាំងរម្លឹក ឬ កម្លាំងសកម្ម (restoring force) សមាមាត្រទៅនឹងបម្លាស់ទីពីទីតាំងលំនឹង។

$F_x = -kx$

$$F_x = -kx = ma_x = m\frac{d^2x}{dt^2}$$

កន្សោមបម្លាស់ទី (អេឡុងកាស្យុង)

$$x(t) = x_{\max}\cos(\omega t + \phi)$$

### របៀបកំណត់ផាសដើម

អោយ $x_{max}$ = ឯកតា $\omega = 1$ rad/s, $\phi = 0$ rad យើង បាន $x(t) = \cos(t)$




-ប្រេកង់មុំ ឬ ពុលសាស្យុង

$$\omega = \frac{2\pi}{T} = \sqrt{\frac{m}{k}}$$ ដែល $m \to$ kg និង $k \to$ N/m

# មេរៀនទី១ រលកមេកានិច (រំលឹក ចលនាខួប)

## 3. ចលនាអាកម៉ូនិចងាយ ផ្សេងៗ















# ឧទាហរណ៍

ចូរកំណត់ផាសដើមនៃរូបខាងស្តាំ បើ

$x(t) = x_{\max}\cos(\omega t + \phi)$













# កិច្ចការ

កិច្ចការ3

ចូរកំណត់ផាសដើមនៃរូបខាងស្តាំ បើ

$x(t) = x_{\max}\sin(\omega t + \phi)$












# កិច្ចការ

កិច្ចការ4

សូមមើលរូបខាងស្តាំ ដុំម៉ាសផ្លាស់ទីទៅវិញទៅមកជាដោយមានបម្លាស់ទីជាអនុមន៍ស៊ីនុយសូអ៊ីត។ តាមរយៈតម្លៃខាងក្រោមនេះ តើ $x$ វិជ្ជមាន ឬ អវិជ្ជមាន ឬ សូន្យ? (សម្គាល់៖ ទីតាំងលំនឹង $x = 0$)

(ក) $v_x > 0$ និង $a_x > 0$

(ខ) $v_x > 0$ និង $a_x < 0$

(គ) $v_x < 0$ និង $a_x > 0$

(ឃ) $v_x < 0$ និង $a_x < 0$

(ង) $v_x = 0$ និង $a_x < 0$

(ច) $v_x > 0$ និង $a_x = 0$ ។




# កិច្ចការ

កិច្ចការ5

ក្នុងចលនាអាក់ម៉ូនិចងាយ

$$x(t) = x_{\max}\cos(\omega t + \phi)$$

បើនៅខណៈដើមពេល $x(t = 0) = x_0$, $v(t = 0) = v_{0x}$




ចូរស្រាយបញ្ជាក់ទំនាក់ទំនងខាងក្រោម

$$\phi = \arctan\left(-\frac{v_{0x}}{\omega x_0}\right) \qquad A = \sqrt{x_0^2 + \frac{v_{0x}^2}{\omega^2}}$$

# ឯកសារយោងបន្ថែម

ជំនួស $t = 10s$ ក្នុង (2) យើងបាន $x = 50m/s \times 10s$

$x = 500m$

ជំនួស $x$ និង $h$ ក្នុង (1) យើងបាន $\tan\alpha = \frac{500m}{490m} \Rightarrow \tan\alpha = 1.02$

ដូចនេះ យើងបាន $\boxed{\alpha = 45°34'}$ ។

ខ. តម្លៃនៃវ៉ិចទ័រល្បឿននៅខណៈដែលអ្នកជួយសង្គ្រោះមកដល់ផ្ទៃទឹក

ចំពោះវ៉ិចទ័រល្បឿនតាមទិសដេកមិនប្រែប្រួលទេ

យើងបាន $v_x = v_0 = 50.0m/s$

ឯវ៉ិចទ័រល្បឿនតាមទិសឈរប្រែប្រួលតាមពេល ព្រោះតាមទិសឈរចលនានោះជាចលនាទន្លាក់សេរី

យើងបាន $v_y = (v_0 \sin\theta) + gt = gt$ ឬ $v_y = (9.8m/s^2)(10s) = 98.0m/s^2$

ដោយ $\vec{v} = (v_x)\vec{i} + (v_y)\vec{j}$ ឬ $v = \sqrt{v_x^2 + v_y^2} = \sqrt{(50.0m/s)^2 + (98.0m/s)}^2$

ដូចនេះ $v = 110m/s$

យើងមាន $\cos\theta = \frac{v_x}{v} = \frac{50.0m/s}{110m/s} = 0.45$

ដូចនេះ $\boxed{\theta = 63°15'}$

វ៉ិចទ័រល្បឿនមានតម្លៃ $110m/s$ និងមានទិសបង្កើតបានមុំ $\theta = 63°15'$ ជាមួយទិសដេក ។

## 3.2. ចលនាវង់ស្មើ

### ក. សមីការពេល

ចលនាមួយជាចលនាវង់ស្មើ កាលណាចល័តផ្លាស់ទីលើវង់មួយដោយវ៉ិចទ័រល្បឿនរក្សាតម្លៃថេរ ។

ឧបមានៅខណៈ $t = 0$ ចល័តនៅត្រង់ទីតាំង $M_0$ និងខណៈ $t$ ចល័តនៅត្រង់ $M$ ។ គេបាន $\overset{\frown}{AM} = S$ ហៅថាអាប់ស៊ីសកោង ហើយមានសមីការជាអនុគមន៍ដឺក្រេទី 1 $\boxed{S = vt + S_0}$ (1) ដែល $S_0 = \overset{\frown}{AM_0}$ អាប់ស៊ីសកោងដើម $S$ និង $S_0$ គិតជា $m$ , $v$ គិតជា $m/s$ និង $t$ គិតជា $s$ ។




រូបទី 1.8 : គន្លងជារង្វង់

## ខ. ល្បឿនមុំ

នៅខណៈ t កាំ OA គៀសបានមុំ $\alpha = (\overrightarrow{OA}, \overrightarrow{OM})$ (1)

បើ r ជាកាំនៃរង្វង់ គេបាន $\alpha = \frac{\overset{\frown}{AM}}{r} = \frac{s}{r}$ (2)

ជំនួស (1) ក្នុង (2) គេបាន $\frac{s}{r} = \frac{v}{r}t + \frac{s_0}{r}$ ដោយ $\frac{s}{r} = \alpha$ និង $\frac{s_0}{r} = \alpha_0$

ដូចនេះ $\alpha = \frac{v}{r} \times t + \alpha_0$ (3)

ឬ $\frac{\alpha - \alpha_0}{t} = \frac{v}{r}$ ហៅថាមុំគៀសក្នុងរយៈពេលមួយវិនាទី ។

យើងបានសិក្សារួចមកហើយពីល្បឿនប្រវែង $v$ គឺជាចម្ងាយចរក្នុងរយៈពេលមួយវិនាទី ដូចគ្នាដែរមុំគៀសក្នុងរយៈពេលមួយវិនាទីហៅថា ល្បឿនមុំដែលតាងដោយ ω ។

គេបាន $\omega = \frac{v}{r}$ ឬ $v = r\omega$ ជំនួស $\omega = \frac{v}{r}$ ក្នុង (3)

ដូចនេះ $\boxed{\alpha = \omega t + \alpha_0}$ α និង $\alpha_0$ គិតជា rd, ω គិតជា rd/s ។

កាលណាចល័តផ្លាស់ទីដោយល្បឿនធំ គេគិតល្បឿនមុំជាចំនួនជុំក្នុងមួយវិនាទី ។

យើងបាន $\boxed{\omega = 2\pi N}$ ω គិតជា rd/s, N គិតជា ចំនួនជុំក្នុងវិនាទី ។

កាលណាចល័តផ្លាស់ទីបានមួយជុំ ($2\pi r$) ដោយល្បឿន $v$ ខួប T (រយៈពេលដែលចល័តផ្លាស់ទីមួយជុំ) គេបាន

$T = \frac{2\pi r}{v}$ តែដោយ $\frac{v}{r} = \omega$

$T = \frac{2\pi}{\omega}$ ដោយ $\omega = 2\pi N$ $\Rightarrow$ $\frac{1}{N} = \frac{2\pi}{\omega}$

ដូចនេះ $\boxed{T = \frac{1}{N}}$ ។

## គ. សំទុះ

ក្នុងចលនាកោងវ៉ិចទ័រសំទុះ $\vec{a}$ ជាផលបូកធរណីមាត្រនៃសំទុះផ្ទុំប៉ះ $\vec{a}_T$ និងសំទុះផ្ចិតកែង $\vec{a}_N$ ។

យើងបាន $\vec{a} = \vec{a}'_N + \vec{a}_T$

ក្នុងចលនាវង់ស្មើល្បឿនប្រវែង $\vec{v}$ មានតម្លៃថេរ

ដូចនេះ $\vec{a}_T = 0$ $\Rightarrow$ $\vec{a} = \vec{a}_N$

ក្នុងចលនាវង់ស្មើ សំទុះនៅគ្រប់ចំណុចទាំងអស់នៃគន្លងជាវ៉ិចទ័រដែលមានទិសដៅតម្រង់ទៅរកផ្ចិត O ហើយមានតម្លៃថេរ ។



រូបទី 1.9 : សំទុះនៃចលនាវង់ស្មើ

### ឃ. ចំណោលចលនាវង់ស្មើលើអ័ក្ស $\overrightarrow{Ox}$ និង $\overrightarrow{Oy}$



រូបទី 1.10 : ចំណោលវ៉ិចទ័រល្បឿន

យើងមានទំនាក់ទំនង $\cos\theta = \frac{x_M}{r}$ និង $\sin\theta = \frac{y_M}{r}$

ដោយ $\vec v = \vec v_x + \vec v_y$ និង $v_x = -v\sin\theta = \frac{v}{r}y_M$

និង $v_y = v\cos\theta = \frac{v}{r}x_M$

យើងបាន $\vec v = \left(-\frac{v}{r}\, y_M\right)\vec i + \left(\frac{v}{r}\, x_M\right)\vec j$

សំទុះមធ្យម $\vec a_{av} = \frac{\Delta \vec v}{\Delta t}$ ឬ $\vec a_{av} = \left(-\frac{v}{r}\frac{\Delta y}{\Delta t}\right)\vec i + \left(\frac{v}{r}\frac{\Delta x}{\Delta t}\right)\vec j$



រូបទី 1.11 : ចំណោលសំទុះ

តាមទំនាក់ទំនង $\frac{\Delta y}{\Delta t}$ កាលណា $\Delta t$ ខិតទៅរកសូន្យ $\Delta y$ ក៏ខិតទៅរកសូន្យ យើងបាន $\frac{\Delta y}{\Delta t}$ ខិតទៅរកតម្លៃកម្រិតដែលតាងដោយវ៉ិចទ័រល្បឿនខណៈ $v_y$ ។ ដូចគ្នាដែរចំពោះ $\frac{\Delta x}{\Delta t}$ ក៏ខិតទៅរកតម្លៃកម្រិតដែលតាងដោយវ៉ិចទ័រល្បឿនខណៈ $v_x$ ។

ដូចនេះ យើងបានសំទុះខណៈ

$$\vec a = \left(-\frac{v}{r}v_y\right)\vec i + \left(\frac{v}{r}v_x\right)\vec j = \left(-\frac{v^2}{r}\cos\theta\right)\vec i + \left(-\frac{v^2}{r}\sin\theta\right)\vec j$$

ដោយ $\vec a_x \perp \vec a_y$

យើងបាន $a = \sqrt{a_x^2 + a_y^2}$ ឬ $a = \sqrt{\left(-\frac{v^2}{r}\cos\theta\right)^2 + \left(-\frac{v^2}{r}\sin\theta\right)^2}$

$a = \frac{v^2}{r}\sqrt{\cos^2\theta + \sin^2\theta}$ ដោយ $\sin^2\theta + \cos^2\theta = 1$

ដូចនេះ $\boxed{a = \frac{v^2}{r}}$ នេះជាតម្លៃនៃសំទុះចូលផ្ចិត ។

***ឧទាហរណ៍*** : អង្គធាតុមួយមានចលនាវង់ស្មើដោយល្បឿនថេរ $10\,m/s$ ។ គន្លងវង់នោះមានកាំ $15\,m$ ។ រកសំទុះចូលផ្ចិតនៃចលនារបស់អង្គធាតុនោះ ។

✍ ដំណោះស្រាយ

សំទុះចូលផ្ចិត

តាមរូបមន្ត $a = \frac{v^2}{r}$ ដោយ $r = 15\,m$ និង $v = 10\,m/s$

យើងបាន $a = \frac{(10\,m/s)^2}{15\,m} = 6.7\,m/s^2$

ដូចនេះ $\boxed{a = 6.7\,m/s^2}$ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys

# 4. វិុចទ័រល្បឿនធៀបនិងសំទុះធៀប

## ក. វ៉ិចទ័រល្បឿនធៀប



*រូបទី 1.12 : ទីតាំងរបស់ចល័ត*

ឧបមាគេមានប្រព័ន្ធយោងពីរ $S_1$ (នៅនឹង)និង $S_2$ ផ្លាស់ទីដោយវ៉ិចទ័រល្បឿនថេរ $\vec{v}_0$ ។

នៅខណៈ t ចល័តនៅត្រង់ទីតាំងM ធៀបនឹងប្រព័ន្ធយោង $S_1$ យើងអាចសរសេរ $\vec{r}_1 = \vec{v}_0 t + \vec{r}_2$ ។

បើធៀបនឹងប្រព័ន្ធយោង $S_2$ យើងបាន $\vec{r}_2 = \vec{r}_1 - \vec{v}_0 t$

ចំពោះវ៉ិចទ័រល្បឿនមធ្យមរបស់ចល័តនៅខណៈ t

យើងអាចសរសេរ $\vec{v}_{av} = \dfrac{\Delta\vec{r}_2}{\Delta t} = \dfrac{\Delta\vec{r}_1}{\Delta t} - \dfrac{\Delta(\vec{v}_0 t)}{\Delta t}$

$\vec{v}_{av} = \vec{v}_1 - \vec{v}_0$

កាលណា Δt ខិតទៅរកសូន្យ $\dfrac{\Delta\vec{r}_1}{\Delta t}$ ខិតទៅរកវ៉ិចទ័រល្បឿនខណៈ $\vec{v}_1$ និង $\dfrac{\Delta\vec{r}_2}{\Delta t}$ ក៏ខិតទៅរកតម្លៃនៃវ៉ិចទ័រល្បឿនខណៈដែរគឺ $\vec{v}_2$ ។

ដូចនេះយើងបាន $\vec{v}_2 = \vec{v}_1 - \vec{v}_0$

$\vec{v}_1$ ជាវ៉ិចទ័រល្បឿនខណៈរបស់ចល័តធៀបនឹងប្រព័ន្ធ $S_1$

$\vec{v}_2$ ជាវ៉ិចទ័រល្បឿនខណៈរបស់ចល័តធៀបនឹងប្រព័ន្ធ $S_2$

$\vec{v}_0$ ជាវ៉ិចទ័រល្បឿនរបស់ប្រព័ន្ធ $S_2$ ធៀបនឹងប្រព័ន្ធ $S_1$

$v_0$ , $v_1$ និង $v_2$ ត្រូវគិតជា m/s ។

## ខ. សំទុះធៀប

តាមទំនាក់ទំនង $\vec{v}_2 = \vec{v}_1 - \vec{v}_0$ យើងអាចសរសេរសំទុះមធ្យម $\vec{a}'_{av} = \dfrac{\Delta\vec{v}'}{\Delta t} = \dfrac{\Delta\vec{v}}{\Delta t} - \dfrac{\Delta\vec{v}_0}{\Delta t}$

តែ $\Delta\vec{v}_0 = \vec{0}$ យើងបាន $\vec{a}'_{av} = \vec{a}_{av}$ ។ កាលណា Δt ខិតទៅរកសូន្យ $\dfrac{\Delta v'}{\Delta t}$ ខិតទៅរកតម្លៃនៃសំទុះខណៈ a′ និង $\dfrac{\Delta v}{\Delta t}$ ខិតទៅរកតម្លៃនៃ a គេបាន $\vec{a}' = \vec{a}$ ។ ដូចនេះ សំទុះខណៈដែលវាស់ដោយអ្នកសង្កេតនៅនឹង ដូចគ្នានឹងសំទុះខណៈវាស់ដោយអ្នកសង្កេតដែលមានចលនាដោយវ៉ិចទ័រល្បឿនថេរធៀបនឹងអ្នកសង្កេតនៅនឹង ។

# មេរៀនទី១ រលកមេកានិច

2024

## ១. ប្រភេទរលកមេកានិច

រលកមេកានិច



(ត្រូវការមជ្ឈដ្ឋានដំណាល)

រលកអេឡិចត្រូម៉ាញេទិច



(មិនត្រូវការមជ្ឈដ្ឋានដំណាល)

រលកមេកានិច ជារញ្ជួយដែលដាលឆ្លងកាត់រូបធាតុ ឬសារធាតុមួយដែលហៅថា មជ្ឈដ្ឋានដំណាល។

# ១. ប្រភេទរលកមេកានិច

ទម្រង់រលក




រលកទទឹង
( Transverse Wave )




រលកបណ្តោយ
( Longitudinal Wave )

- **រលកទទឹង** ជារលកដែលចលនានៃមជ្ឈដ្ឋានរូបធាតុ មានគន្លងកែងនឹង ទិសនៃដំណាល។
- **រលកបណ្តោយ** ជារលកដែលមានចលនានៃមជ្ឈដ្ឋានរូបធាតុ តាមទិសនៃដំណាល។

# ១. ប្រភេទរលកមេកានិច

ទម្រង់រលក



# ២. រលកខូប

## រលកទទឹងខូប







- រលកខូប អាចតាងដោយផលបូកនៃ រលកស៊ីនុយសូអ៊ីតច្រើន។
- ពេលរលកស៊ីនុយសូអ៊ីត ដាលក្នុងមជ្ឈដ្ឋានណាមួយ រាល់ភាគល្អិតក្នុងមជ្ឈដ្ឋានស្ថិតក្នុងចលនាអាកម៉ូនិចងាយ ដែលមានប្រេកង់ថេរ។
- រលកខូប

$$v = \lambda f$$

$v$: ល្បឿនដំណាល (m/s)
$\lambda$: ជំហានរលក (m)
$f$: ប្រេកង់ (Hz ឬ $s^{-1}$)

# ២. រលកខូប

## រលកទទឹងខូប: ចលនារលក និង ចលនាភាគល្អិត







រលកបញ្ជូនថាមពលពីទីតាំងមួយទៅទីតាំងមួយ ប៉ុន្តែមិនបញ្ជូនភាគល្អិតដែលនៅក្នុងមជ្ឈដ្ឋានទេ។

# ២. រលកខួប

## រលកបណ្តោយខួប




ល្បឿនដំណាល

$$v = \lambda f$$

# ៣. ការពិពណ៌នាបែបគណិតវិទ្យាអំពីរលក




## អនុគមន៍រលកនៃរលកស៊ីនុយសូអ៊ីត

$y = y(x,t)$ ជាអនុគមន៍រលក [វាជាបម្លាស់ទីនៃភាគល្អិតត្រង់ទីតាំង $x$ នៅខណៈ $t$ ណាមួយ]

- បម្លាស់ទីរបស់ភាគល្អិតត្រង់ $x = 0$

$$y(x=0,t) = A\cos\omega t = A\cos 2\pi f t$$

- រលកដាលពីចំណុច $x = 0$ ទៅដល់ចំណុច $x$ ណាមួយដោយប្រើពេល $\frac{x}{v}$ នោះចលនាត្រង់ ចំណុច $x$ នៅ ខណៈ $t$ គឺដូចទៅនឹងចលនារបស់ចំណុច $x = 0$ នៅខណៈ $t - \frac{x}{v}$ មុន។ យើងអាចសរសេរសមីការបម្លាស់ទីចំណុច $x$ នៅ ខណៈ $t$

$$y(x,t) = A\cos\left[\omega\left(t - \frac{x}{v}\right)\right]$$

ដោយ ប្រើលក្ខណៈ $\cos(-\theta) = \cos(\theta)$ នោះយើងបាន $y(x,t) = A\cos\left[\omega\left(\frac{x}{v} - t\right)\right]$

# ៣. ការពិពណ៌នាបែបគណិតវិទ្យាអំពីរលក




## អនុគមន៍រលកនៃរលកស៊ីនុយសូអ៊ីត

ទម្រង់ផ្សេងទៀត

$$y(x,t) = A\cos\left[2\pi\left(\frac{x}{\lambda} - \frac{t}{T}\right)\right] \quad \text{[រលកដាលទៅទិសដៅ } +x\text{]}$$

ទំនាក់ទំនងផ្សេង

ចំនួនរលក $k \equiv 2\pi/\lambda$ ហើយ $\omega = vk$

នោះអនុគមន៍រលក

$$y(x,t) = A\cos(kx - \omega t)$$

ខ្នាត

$$k \rightarrow \text{rad/m}$$

$$\omega \rightarrow \text{rad/s}$$

# ៣. ការពិពណ៌នាបែបគណិតវិទ្យាអំពីរលក

## ការគូសក្រាបអនុគមន៍រលក

(a) If we use Eq. (15.7) to plot $y$ as a function of $x$ for time $t = 0$, the curve shows the *shape* of the string at $t = 0$.




បើយើងគូសក្រាប $y$ ទល់នឹង $x$ នៅខណៈ t ណាមួយ នោះយើងបានរូបរាងខ្សែ

ឧទាហរណ៍: ខណៈ $t = 0, y(x,0) = A\cos(kx) = A\cos\left(2\pi\frac{x}{\lambda}\right)$

(b) If we use Eq. (15.7) to plot $y$ as a function of $t$ for position $x = 0$, the curve shows the *displacement* $y$ of the particle at $x = 0$ as a function of time.




បើយើងគូសក្រាប $y$ ទល់នឹង $t$ នៅត្រង់ចំណុច $x$ ណាមួយ នោះយើងបានបម្លាស់ទីនៃ ចំណុច $x$ ជាអនុគមន៍នៃពេល

ឧទាហរណ៍: ខណៈ $x = 0, y(0,t) = A\cos(\omega t) = A\cos\left(2\pi\frac{t}{T}\right)$

# ៣. ការពិពណ៌នាបែបគណិតវិទ្យាអំពីរលក

### អនុគមន៍រលកនៃរលកស៊ីនុយសូអ៊ីតដាលទៅទិសដៅ $-x$

- រលកដាលពីចំណុច $x = 0$ ទៅដល់ចំណុច $x$ ណាមួយដោយប្រើពេល $\frac{x}{v}$ នោះចលនាត្រង់ ចំណុច $x$ នៅ ខណៈ $t$ គឺដូចទៅនឹងចលនារបស់ចំណុច $x = 0$ នៅខណៈ $t + \frac{x}{v}$ ក្រោយមក។ យើងអាចសរសេរសមីការបម្លាស់ទីចំណុច $x$ នៅ ខណៈ $t$

$$y(x,t) = A\cos\left[\omega\left(t + \frac{x}{v}\right)\right] = A\cos\left[2\pi\left(\frac{x}{\lambda} + \frac{t}{T}\right)\right] = A\cos(kx + \omega t)$$

ល្បឿនរលកគឺជាល្បឿនដែលក្នុងនោះយើងត្រូវតាមដានចំណុចមួយដែលមានតម្លៃផាសថេរ ដូច ជាបាតរលក កំពូលរលកជាដើម។

$$\text{ផាស} = kx \mp \omega t = \text{ថេរ}$$

$v = \frac{dx}{dt} = \pm\frac{\omega}{k}$ [ពេលខ្លះគេហៅវាថាជាល្បឿនផាស]

# ៣. ការពិពណ៌នាបែបគណិតវិទ្យាអំពីរលក

### វ៉ិចទ័រល្បឿន និង សំទុះនៃភាគល្អិតក្នុង រលកស៊ីនុយសូអ៊ីត

- ល្បឿនទទឹងនៃភាគល្អិត ( $v_y$ ) ករណីរលកដាលទៅខាងស្តាំ

$y(x,t) = A\cos(kx - \omega t)$

$$v_y(x,t) = \frac{\partial y(x,t)}{\partial t} = \omega A\sin(kx - \omega t)$$

$$= v_{y,\max}\sin(kx - \omega t)$$

សញ្ញា $\partial/\partial x$ មានន័យថាដេរីវេដោយផ្អែកធៀបនឹង $x$ ដោយចាត់ទុក $t$ ថេរ

- ស្រដៀងគ្នានេះដែរយើងទទួលបានសំទុះ

$$a_y = \frac{\partial v_y(x,t)}{\partial t} = \frac{\partial^2 y(x,t)}{\partial t^2} = -\omega^2 A\cos(kx - \omega t)$$

$$= -\omega^2 y(x,t)$$

- មេគុណប្រាប់ទិស $= \frac{\partial y(x,t)}{\partial x}$
- កំណោងនៃខ្សែ $= \frac{\partial^2 y(x,t)}{\partial x^2}$




$$\frac{\partial^2 y(x,t)}{\partial x^2} = -k^2 A\cos(kx - \omega t) = -k^2 y(x,t)$$

នោះយើងបាន $\frac{\partial^2 y(x,t)/\partial t^2}{\partial^2 y(x,t)/\partial x^2} = \frac{\omega^2}{k^2} = v^2$

### សមីការរលក

$$\frac{\partial^2 y(x,t)}{\partial x^2} = \frac{1}{v^2}\frac{\partial^2 y(x,t)}{\partial t^2}$$

# ៣. ការពិពណ៌នាបែបគណិតវិទ្យាអំពីរលក

វ៉ិចទ័រល្បឿន និង សំទុះនៃភាគល្អិតក្នុង រលកស៊ីនុយសូអ៊ីត




# ៤. ល្បឿននៃរលកទទឹង

$v=\sqrt{F/\mu}$ [$F$ តំណឹងខ្សែគិតជា N, $\mu$ ដង់ស៊ីតេម៉ាសក្នុងមួយខ្នាតប្រវែង kg/m]

ល្បឿនរលកនៅលើខ្សែ៖ វិធីសាស្ត្រទី១

- នៅខណៈ $t=0$ យើងអនុវត្តកម្លាំង $F_y$ ក្នុងរយៈពេល $t$ ណាមួយ នោះកំណាត់ខ្សែដែលមានម៉ាសសរុប $m$ ផ្លាស់ទីដោយល្បឿន $v_y$ ឡើងលើ ហើយចលនារញ្ជួយដាលដោយល្បឿន $v$ តាមទិសដេក

អាំពុលស្យុង = បម្រែបម្រួលបរិមាណចលនា

$$\left.\begin{aligned} F_y t &= m v_y \\ m v_y &= (\mu v t) v_y \end{aligned}\right\} F_y = \mu v v_y$$




លក្ខណៈត្រីកោណកែង $\frac{F_y}{F}=\frac{v_y t}{vt}$ យើងបាន $\frac{\mu v v_y}{F}=\frac{v_y}{v}\to v=\sqrt{F/\mu}$

# ៤. ល្បឿននៃរលកទទឹង

$v=\sqrt{F/\mu}$ [$F$ តំណឹងខ្សែគិតជា N, $\mu$ ដង់ស៊ីតេម៉ាសក្នុងមួយខ្នាតប្រវែង kg/m]




## ល្បឿនរលកនៅលើខ្សែ៖ វិធីសាស្ត្រទី២

ម៉ាសកំណាត់ខ្សែ $m=\mu\,\Delta x$

$-\frac{F_{1y}}{F}$ ស្មើទៅនឹងមេគុណប្រាប់ទិស $=\left(\frac{\partial y}{\partial x}\right)_x$

$\frac{F_{2y}}{F}$ ស្មើទៅនឹងមេគុណប្រាប់ទិស $=\left(\frac{\partial y}{\partial x}\right)_{x+\Delta x}$

នោះកម្លាំងសរុបតាមអ័ក្ស $y$

$$F_y=F\left[\left(\frac{\partial y}{\partial x}\right)_{x+\Delta x}-\left(\frac{\partial y}{\partial x}\right)_x\right]=\mu\Delta x\frac{\partial^2 y}{\partial t^2}$$

$$\frac{\left[\left(\frac{\partial y}{\partial x}\right)_{x+\Delta x}-\left(\frac{\partial y}{\partial x}\right)_x\right]}{\Delta x}=\frac{\mu}{F}\frac{\partial^2 y}{\partial t^2}\longrightarrow \lim_{\Delta x\to 0}\frac{\left[\left(\frac{\partial y}{\partial x}\right)_{x+\Delta x}-\left(\frac{\partial y}{\partial x}\right)_x\right]}{\Delta x}=\frac{\partial^2 y}{\partial x^2}=\frac{1}{v^2}\frac{\partial^2 y}{\partial t^2}\longrightarrow v=\sqrt{F/\mu}$$

ឯកសារយោងបន្ថែម

**មេរៀនទី**

# 2 រលក

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាបានច្បាស់លាស់ពីប្រភេទនិងលក្ខណៈរបស់រលក ។
- បង្ហាញពីទម្រង់របស់រលក ។
- ពន្យល់បានច្បាស់នូវចលនារលកដែលមានរាងអាស្រ័យនឹងមជ្ឈដ្ឋានដំណាល ។
- ពណ៌នាពីបម្រែបម្រួលទិសដៅដំណាលរបស់រលក ។
- បកស្រាយបាននូវសមីការរលកស៊ីនុយសូអ៊ីត ។

## 1. សេចក្តីផ្តើម

យើងបានដឹងខ្លះៗ ពីចលនារបស់រលកដែលមានលក្ខណៈជាលំយោល ។ រលកមានពីរប្រភេទ គឺ រលកមេកានិចនិងរលកអេឡិចត្រូម៉ាញេទិច ។

ប្រភេទរលកដែលយើងលើកយកមកសិក្សា ក្នុងមេរៀននេះ ជាប្រភេទរលកមេកានិច ។ រាល់ចលនារលកទាំងនេះដាលឆ្លងកាត់មជ្ឈដ្ឋាន ខ្យល់ ទឹក ខ្សែ រ៉ឺសរ ... ។ ***ឧទាហរណ៍*** បើយើងពិនិត្យមើលនូវការរលាស់ខ្សែ កន្ទេល ឬព្រំវែងៗ (មានភាពទន់យឺត) យើងឃើញរលកដាលតាមបណ្តោយរហូតដល់ចុងម្ខាង (រូបទី 2.1) ។



***រូបទី 2.1***

យើងសង្កេតមើលចលនារបស់ទឹកនៅពេលដែលយើងទម្លាក់ដុំគ្រួសមួយដុំទៅលើផ្ទៃទឹកដែលឋិតនៅនឹងថ្កល់ នៅពេលដែលគ្រាប់គ្រួសធ្លាក់ចុះប៉ះនឹងផ្ទៃទឹក ។ យើងឃើញផ្ទៃទឹកមាន រូបរាងរញ្ជួយជារលករង់ ហើយដាលនៅលើផ្ទៃទឹកជាបន្តបន្ទាប់ដោយរីកកាន់តែធំឡើងៗ រួចក៏រលាយបាត់ទៅ ។

## 2. រលកទទឹងនិងរលកបណ្តោយ

រលកមេកានិចជារលកដែលដាលកាត់មជ្ឈដ្ឋានរូបធាតុ (រឹង រាវ ឧស្ម័ន) ដែលល្បឿនរបស់វាអាស្រ័យនឹងមជ្ឈដ្ឋានដំណាល ។ រលកមានទម្រង់ពីរគឺ រលកទទឹងនិងរលកបណ្តោយ ។

### 2.1. រលកទទឹង

យើងពិនិត្យមើលនូវឧទាហរណ៍ខាងលើស្តីពីការរលាស់ខ្សែកន្ទេល ឬព្រំវែងៗ យើងឃើញថារលកដាលតាមបណ្តោយខ្សែរហូតដល់ខាងចុងម្ខាង ។

ឥឡូវយើងដៅចំណុច M លើខ្សែយឺតសន្ធឹងវែង យើងនឹងរលាស់ចុងទំនេរ(រូបទី 2.2) ។យើងសង្កេតចលនាចំណុច M នៅខណៈរលកទៅដល់ ។ យើងឃើញថាចំណុច M ធ្វើចលនាឡើងចុះនៅនឹងកន្លែង រួចនៅស្ងៀមវិញ រីឯរលកក៏ដាលហួសទៅ ។




***រូបទី 2.2***

បើយើងធៀបទិសបំលាស់ទីនៃចំណុច M ទៅនឹងទិសដំណាល យើងឃើញថា ទិសទាំងពីរនេះកែងគ្នា ។ តាមការសង្កេតយើងឃើញថា រលកដែលមាន**ចលនារញ្ជួយនៃចំណុចនីមួយៗក្នុងមជ្ឈដ្ឋានរូបធាតុ ដែលមានគន្លងកែងនឹងទិសដំណាលជារលកទទឹង** ។ ***ឧទាហរណ៍*** កំសួលសន្ទូចឬផ្នុកដបដែលអណ្តែតនៅលើផ្ទៃទឹក វត្ថុទាំងនេះគ្រាន់តែឡើងចុះៗ នៅនឹងមួយកន្លែងពេលរលកទៅប៉ះវា ។

### 2.2. រលកបណ្តោយ




***រូបទី 2.3***

យើងសន្ធឹងរ៉ឺសរមួយដែលយឺតល្អប្រវែងប្រហែល 8m ។ នៅចុងម្ខាងយើងបង្រួមស្ពៀប្អូនប្រាំឱ្យខិតជិតគ្នា រួចលែងវិញ យើងឃើញហាក់ដូចជាកញ្ចុំស្ពៀទាំងនេះរត់រហូតដល់ចុងម្ខាងទៀត នៃរ៉ឺសរ (រូបទី 2.3) ។ បើយើងដៅចំណាំស្ពៀតែមួយ ហើយសង្កេតចលនាស្ពៀនោះនៅពេលមានរញ្ជួយទៅដល់ យើងនឹងឃើញថា ស្ពៀនោះគ្រាន់តែធ្វើចលនាទៅមកតាមបណ្តោយរ៉ឺសរនៅតែមួយកន្លែង ។ ដូចនេះ រលកដែលមានរញ្ជួយតាមទិស

ដំណាលរញ្ជួយ រលកដែលកើតឡើងជា **រលកបណ្ដោយ** ។ ***ឧទាហរណ៍*** គ្រាប់ដូមីណូដែលដាក់តម្រៀបគ្នាជាជួររួចត្រូវរុញឱ្យវាដួល ។

***សន្និដ្ឋាន***

- ពេលដែលរលកដាលឆ្លងកាត់មជ្ឈដ្ឋានរូបធាតុមួយ រញ្ជួយគ្មានជញ្ជូនសារធាតុនៃមជ្ឈដ្ឋាននេះទៅជាមួយឡើយ ។ ***ឧទាហរណ៍*** យើងមើលកំសួលសន្ទូចឬផ្នុកជបដែលអណ្ដែតនៅលើផ្ទៃទឹកយើងឃើញថា វត្ថុទាំងនេះគ្រាន់តែឡើងចុះនៅពេលរលកទៅប៉ះ ។
- រលកតែងតែនាំថាមពលទៅជាមួយក្នុងពេលដាល ហើយវាក៏បាត់បង់ទៅវិញ ។

***ឧទាហរណ៍ :*** ការរលាស់ចុងខ្សែឬចុងកន្ទេល នៅពេលដែលយើងរលាស់វា យើងឃើញថាចំណុចដើមដែលបានដៅចំណាំទទួលមុន បន្ទាប់មកក៏បញ្ជូនថាមពលទៅចំណុចមួយទៀតដែលស្ថិតនៅបន្តបន្ទាប់ក្នុងទិសដំណាល ហើយក៏បញ្ជូនថាមពលនោះទៅបន្តបន្ទាប់គ្នារហូតដល់ខាងចុង រួចហើយនៅស្ងៀម ។

## 2.3. ល្បឿនដំណាលនៃរលក



***រូបទី 2.4***

យើងសាកល្បងកំណត់ល្បឿនដំណាលនៅក្នុងមជ្ឈដ្ឋានមួយ ។ ការសិក្សាអំពីរលកដាលនៅលើខ្សែយឺត យើងបានដៅចំណាំចំណុចខ្លះដូចជា $M_1$ , $M_2$ , $M_3$ , $M_4$ នៅលើខ្សែនោះ ។ រលកមកដល់ $M_1$ នៅខណៈ $t_1$ ដល់ $M_2$ នៅខណៈ $t_2$ ដល់ $M_3$ នៅខណៈ $t_3$ ដល់ $M_4$ នៅខណៈ $t_4$ (រូបទី 2.4.ក) ។ បើយើងចែកចម្ងាយដែលរលកបានដាលនឹងរយៈពេល យើងឃើញថាផលចែកមានតម្លៃស្មើៗគ្នា យើងបាន

$$\frac{M_1M_2}{t_2-t_1} = \frac{M_2M_3}{t_3-t_2} = \frac{M_3M_4}{t_4-t_3} = \ldots = v = \text{ថេរ}$$

លទ្ធផលនេះបង្ហាញថា រលកដាលដោយចលនាត្រង់ស្មើ ។ ចំណុចទាំងឡាយក្នុងទិសដំណាលធ្វើចលនាដូចគ្នានឹងចំណុចដើម ខុសគ្នាតែត្រង់មុននិងក្រោយប៉ុណ្ណោះ ។ បើគេស្គាល់ល្បឿនដំណាល $v$ គេអាចដឹងថាចំណុច M ដែលនៅលើខ្សែចម្ងាយ $x$ ពីចំណុចដើម O ហើយធ្វើចលនាដូច O ក្រោយរយៈពេល $t = \frac{x}{v}$ បន្ទាប់ពី O (រូបទី 2.4.ខ) ។

***ឧទាហរណ៍ :*** បន្ទះថែបមួយមានចុង O នឹងថ្កល់និងចុង A ភ្ជាប់ទៅនឹងខ្សែដេកមួយដែលមានប្រវែងយ៉ាងវែង ។ គេធ្វើឱ្យបន្ទះថែបនេះមានលំញ័រស៊ីនុយសូអ៊ីតនៅត្រង់ A ដោយល្បឿន $v = 10m/s$ តាមបណ្ដោយខ្សែទៅដល់ចំណុច M មួយ ដែលមានចម្ងាយ $x = 0.25m$ ស៊ីនុយសូអ៊ីតនឹងមាន

youtube.com/moeys
facebook.com/moeys.gov.kh

អំពីទុត A = 1m មិនថយនិងមានសមីការលំយោលនៅត្រង់ចំណុច A : $y_A = \sin(200\pi t)$ និងនៅត្រង់ចំណុច M គឺ $y_M = -\sin(200\pi t)$ ។ ប្រៀបធៀបចលនាលំយោលនៅត្រង់ចំណុច A និងចំណុច M ។

✍ ដំណោះស្រាយ

តាមសម្មតិកម្ម $v = 10m/s$ ; $x = 0.25m$ ; $y_A = \sin(200\pi t)$ ; $y_M = -\sin(200\pi t)$ ។ ដោយ $y_A = \sin(200\pi t)$ និង $y_M = -\sin(200\pi t)$ មានផលសងផាសស្មើនឹង $\pi$ នាំឱ្យសមីការចលនារលកត្រង់ A និងM មានចលនាឈមផាសគ្នា ។ នាំឱ្យយើងបាន $y_A = A\sin\frac{2\pi t}{T} = \sin 200\pi t$ ជាអនុគមន៍ស៊ីនុយសូអ៊ីតនៃពេល t និង $y_M = A\sin 2\pi\left(\frac{t}{T}-\frac{x}{\lambda}\right) = -\sin(200\pi t)$ ក៏អនុគមន៍ស៊ីនុយសូអ៊ីតនៃពេលដែរ កាលណាគេឱ្យតម្លៃពី $1 \rightarrow x$ ហើយមានខួប $T = \frac{1}{100}s$ ។

- ចំពោះ $y_A = \sin(200\pi t)$ :

| t(s) | o | | $\frac{T}{4} = \frac{1}{400}$ | | $\frac{T}{2} = \frac{1}{200}$ | | $\frac{3T}{4} = \frac{3}{400}$ | | $T = \frac{1}{100}$ |
|---|---|---|---|---|---|---|---|---|---|
| $(200\pi t)$ | o | | $\frac{\pi}{2}$ | | $\pi$ | | $\frac{3\pi}{2}$ | | $2\pi$ |
| $y_A(cm)$ | o | ↗ | 1 | ↘ | o | ↗ | −1 | ↘ | o |

- ចំពោះ $y_M = -\sin(200\pi t)$ នៅខណៈយើងបាន

$t = \frac{x}{v} = \frac{0.25m}{10m/s} = 0.025s$ ឬ $t = 2.5T$

ព្រោះចលនារបស់ M កើតមានរយៈពេល t វិនាទីក្រោយចលនារបស់ A ។ ដោយចលនារបស់ M ឈមផាសនឹងចលនារបស់ A (M មានអេឡុងកាស្យុងផ្ទុយពី A ) នៅខណៈមួយ យើងបានក្រាហ្វិកដូចខាងស្តាំ ។




រូបទី 2.5

## 2.4. ជំហានរលក

ក្នុងករណីរញ្ជួយ ជាលំយោលដែលមានខួប T ប្រវែងដែលរលកដាលបានក្នុងមួយខួបគឺ $v.T$ ។ ចម្ងាយចរដែលរលកដាលក្នុងរយៈពេលមួយខួបហៅថា **ជំហានរលក** ។

យើងអាចសរសេរ $\lambda = vT$ ដោយ $T = \frac{1}{f}$ $\Rightarrow$ $v = f\lambda$

ដូចនេះ $\boxed{v = f\lambda}$ $\lambda$ ជំហានរលកគិតជាម៉ែត្រ (m) , v ល្បឿនដំណាលគិតជាម៉ែត្រក្នុងមួយវិនាទី (m/s) , T ខួបនៃចលនាគិតជាវិនាទី (s) និង f ប្រេកង់គិតជាអ៊ែក (Hz) ។

រូបខាងក្រោមនេះបង្ហាញពីដំណាលនៃចលនារលកស៊ីនុយសូអ៊ីតតាមបណ្តោយខ្សែមួយ ។



*រូបទី 2.6*

***ឧទាហរណ៍ :*** ខ្សែមួយមានលំញ័រយោលដោយល្បឿន $v = 34.3\text{m/s}$ និងប្រេកង់ $f = 262\text{Hz}$ ។ គណនាជំហានរលករបស់ខ្សែ ។

✍ ដំណោះស្រាយ

តាមសម្មតិកម្ម $v = 34.3\text{m/s}$ និងប្រេកង់ $f = 262\text{Hz}$

តាមសមីការទំនាក់ទំនងរវាងល្បឿន ជំហានរលក និងប្រេកង់

យើងបាន $v = f\lambda \Rightarrow \lambda = \frac{v}{f} = \frac{34.3\text{m/s}}{262\text{Hz}} = \frac{34.3\text{m/s}^{-1}}{262\text{s}^{-1}} = 0.131\text{m}$

ដូចនេះ ជំហានរលករបស់ខ្សែ $\boxed{\lambda = 0.131\text{m}}$ ។

## 3. លក្ខណៈរលក

រលកមានលក្ខណៈជាចំណាំងផ្លាត ចំណាំងបែរ និងឌីប្រាក់ស្យុង ។ ***ឧទាហរណ៍*** ចុងខ្សែនៅក្នុងខ្យល់ ចុងរ៉ឺសរជាប់នឹងជញ្ជាំង ទឹកបោកផ្ទប់នឹងផ្ទៃរឹងអ្វីមួយ ផ្ទៃញែកទឹក និងខ្យល់ ផ្ទៃញែកទឹកនិងប្រេង ផ្ទៃញែកដី និងថ្ម . . . ជាដើម ។

## ១.1. ចំណាំងផ្លាតនៃរលក

### ក. ចំណាំងផ្លាតនៃរលកវង់



*រូបទី 2.7*

យើងពិនិត្យមើលលើប្រភពនៃលំញ័រ S មួយមានចុងស្រួច ។ យើងដាក់ចុងស្រួចនៃប្រភពនោះឱ្យប៉ប្រះនឹងផ្ទៃទឹកនៅក្នុងផើងមួយ ដែលមានបាតរាងចតុកោណកែង ។កាលណារលកដាលមានរាងរង្វង់ ទៅប៉ះនឹងគែមផើង AB (ដែលមាននាទីជារបាំង) យើងសង្កេតឃើញ ថារលកចាំងផ្លាតមានរាងជាកំណោងវង់ដាលត្រឡប់មកវិញ ហាក់ដូចជាចេញពីផ្ចិត S' មួយដែល ស៊ីមេទ្រីទៅនឹងAB ធៀបនឹង S ក្នុងប្លង់នៃផ្ទៃទឹកនោះ ។ គេវាស់ជំហានរលកចាំងផ្លាតនេះ ឃើញថា ស្មើនឹងរលកចាំងប៉ះ ។រលកចាំងផ្លាតនិងរលកចាំងប៉ះមានល្បឿនដំណាលស្មើៗគ្នា ។

### ខ. ចំណាំងផ្លាតនៃរលកប្លង់



*រូបទី 2.8*

យើងធ្វើពិសោធន៍ម្តងទៀតដោយប្រើកូនបន្ទះឈើ S ជាប្រភពនៃលំញ័រ ហើយដាក់ឱ្យប៉ប្រះនឹងផ្ទៃទឹក(រូបទី 2.8) នៅក្នុងផើងដដែល ។ ប្រភពនៃលំញ័រ S បង្កើតជារលក ដែលយើងសង្កេតមើលឃើញដំណាលរបស់រលកមានរាងដូចជាអង្កត់ត្រង់ដាលជាបន្តបន្ទាប់គ្នាឆ្ពោះទៅទិសមួយកែងនឹងប្លង់នៃប្រភព ។គែមផើងដែលមានតួនាទីជារបាំង AA' **ចាំងផ្លាត**រលកទាំងនេះនៅត្រង់ចំណុច I ឱ្យទៅជារលកចាំងផ្លាតឆ្ពោះទៅរកទិស IS' ។កន្លះបន្ទាត់ IS' បង្កើតជាមួយនឹងខ្សែកែង IN បានមុំចាំងផ្លាត r ស្មើនឹងមុំចាំងប៉ះ i ។

***សម្គាល់ :***

តាមពិសោធន៍ទាំងពីរខាងលើ យើងកត់សម្គាល់ឃើញថា បើរបាំងបំផ្លាតជាប្លង់រាបស្មើ រលកចាំងប៉ះនិងរលកចាំងផ្លាតមានរាងដូចគ្នា ។ ផ្ទុយទៅវិញ បើរបាំងបំផ្លាតមានរាងកោងស្វ៊ែ ឬប៉ារ៉ាបូល ពិសោធន៍បានបង្ហាញថា ៖

- បើរលកចាំងប៉ះជារលកវង់ ដែលមានប្រភពនៅត្រង់ផ្ចិតឬកំនុំរបាំង នោះរលកចាំងផ្លាតជារលករង្វង់ ។
- បើរលកចាំងប៉ះជារលកប្លង់ នោះរលកចាំងផ្លាតជារលកវង់ដែលផ្ចិតនៅត្រង់ផ្ចិតឬកំនុំរបាំង ។
- រាងនៃរលកចាំងផ្លាតប្រែប្រួលតាមរបាំង ។

### 3.2. ចំណាំងបែរនៃរលក

យើងដាក់បន្ទះកែវមួយដែលមានកម្ពស់អាចបន្ថយជម្រៅទឹកបានទៅក្នុងផើងដាក់ទឹកមួយ ។ ផើងនោះមានបាតជម្រាលធ្វើឱ្យជម្រៅទឹកក្នុងផើងមានផ្នែករាក់និងផ្នែកជ្រៅ ។ ឥឡូវយើងដាក់បន្ទះកែវត្រង់ផ្នែកខាងប្រភព រួចធ្វើឱ្យទឹកមានចលនារលកដាលពីតំបន់ទឹកជ្រៅទៅតំបន់ទឹករាក់ ។ ប៉ុន្តែនៅខណៈដែលដាលឆ្លងផុតពីជ្រុងរបស់បន្ទះកែវទៅកន្លែងទឹកជ្រៅរលកប្តូរទិសដៅជំណាល ។ បាតុភូតនេះ គេហៅថា **ចំណាំងបែរនៃរលក** ។




*រូបទី 2.9*

### 3.3. ឌីប្រាក់ស្យុងនៃរលក

យើងឱ្យរលកប្លង់ដាលទៅប៉ះនឹងរបាំងមួយមានប្រវែងវែងជាងជំហានរលក $\lambda$ ។ រលកដែលដាលបន្ត នៅក្រោយរបាំងមានរាងកោងត្រង់ចុងរបាំង ។ បំណត់រលកនៅតាមចុងសងខាងរបាំងជា **ឌីប្រាក់ស្យុងនៃរលក** ។

បើយើងប្តូរយករបាំងឱ្យមានប្រវែងប្រហែលនឹងជំហានរលក $\lambda$ រលកនៅពីក្រោយជិតរបាំងមានរាងកោង ប៉ុន្តែរលកដែលដាលបន្តទៅក៏ជារលកប្លង់ដែរ ។ បាតុភូតឌីប្រាក់ស្យុងមិនធ្វើឱ្យមានបម្រែបម្រួលជំហានរលកទេ ។

បាតុភូតឌីប្រាក់ស្យុងនៃរលកក៏អាចកើតមានផងដែរ កាលណារលកដាលឆ្លងកាត់ចន្លោះឧបសគ្គឬរបាំងពីរ ។ ក្នុងករណីរលកប្លង់ដាលឆ្លងកាត់ចន្លោះឧបសគ្គឬរបាំងពីរដែលស្ថិតនៅឆ្ងាយពីគ្នា $d(d > \lambda)$ បន្ទាប់ពីរងឌីប្រាក់ស្យុងរួចហើយរលកដែលដាលបន្តទៅមុខទៀតក៏ជារលកប្លង់ដែរ ។ ផ្ទុយទៅវិញ បើ $d \approx \lambda$ បន្ទាប់ពីរងឌីប្រាក់ស្យុងរួចរលកប្តូររាងពីរលកប្លង់ទៅជារលករង់ ។

## 4. រលកស៊ីនុយសូអ៊ីត

រលកខ្សែមួយដែលកើតឡើង ដោយប្រភពលំញ័រមួយ ជាចលនាអាកម៉ូនិចងាយត្រូវបានគេហៅថា **រលកស៊ីនុយសូអ៊ីត** ។ នៅពេលដែលរលកខ្សែបានធ្វើចលនាស៊ីនុយសូអ៊ីតពីគល់ O ទៅដល់ចំណុច M មួយតាមបណ្តោយអក្ស ox ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

គល់ O នៃខ្សែត្រូវបានធ្វើចលនាស៊ីនុយសូអ៊ីត ដែលមានខួប T និងអំព្លីទុត A ។

សមីការនៃចលនាអាចសរសេរ $y = A\sin\omega t$




។

ដែល $\omega = \frac{2\pi}{T}$ នាំឱ្យយើងបាន $y = A\sin\frac{2\pi}{T}t$

ឧបមាថា ចំណុច M មានអាប់ស៊ីស $x = OM$ ស្ថិតលើខ្សែ ។ ដំណាលនៃរលកត្រូវបានកើតឡើងសារជាថ្មីនៅត្រង់ M ប៉ុន្តែយឺតជាងនៅត្រង់ចំណុច O ក្នុងរយៈពេល $t'$ ។ បើ v ជាល្បឿននៃដំណាលគេបាន $t' = \frac{x}{v}$ ។ គេអាចនិយាយម្យ៉ាងទៀតថា ចលនារបស់ M នៅខណៈ t គឺជា ចលនា O នៅខណៈ $t - t'$ គេអាចសរសេរ $y = A\sin 2\pi\left(\frac{t-t'}{T}\right)$

$y = A\sin 2\pi\left(\frac{t}{T} - \frac{t'}{T}\right)$ តែ $t' = \frac{x}{v}$

$y = A\sin 2\pi\left(\frac{t}{T} - \frac{x}{vT}\right)$ ដោយ $vT = \lambda$

ដូចនេះចលនានៃចំណុចណាមួយនៅលើខ្សែត្រូវបានតាងដោយសមីការ

$$\boxed{y = A\sin 2\pi\left(\frac{t}{T} - \frac{x}{\lambda}\right)}$$

A អំព្លីទុត , $\lambda$ ជំហានរលក , t រយៈពេល , T ខួប និង x អាប់ស៊ីស ។

***ឧទាហរណ៍ :*** ខ្សែយឺតមួយមានលំញ័រទទឹង ហើយមានទិសដៅវិជ្ជមានតាម x ដោយមានជំហានរលក $\lambda = 40cm$ និងអំព្លីទុត $a = 15cm$ ហើយ និងប្រេកង់ $f = 8Hz$ ដាលចេញពីគល់ទៅដល់ចំណុច M ខណៈ t និង $x = 20$ ។

ក. រកប្រេកង់មុំ ខួបលំយោលនិងល្បឿនរបស់រលក ។

ខ. សរសេរកន្សោមសមីការចលនារបស់រលកនៅត្រង់ចំណុច M ។

## ✍ ដំណោះស្រាយ

ក. រកប្រេកង់មុំ និងខួបលំយោលនៃខ្សែ និងល្បឿនរបស់រលក

តាមសម្មតិកម្ម : ជំហានរលក $\lambda = 40cm$ អំព្លីទុត $a = 15cm$ និងប្រេកង់ $f = 8Hz$

ប្រេកង់ $\omega = 2\pi f = 2\pi(8s^{-1}) = 50rad/s$

ខួបលំយោល $T = \frac{1}{f} = \frac{1}{8s^{-1}} = 0.12s$

ល្បឿនរបស់រលក $v = f\lambda = (40cm)(8s^{-1}) = 320cm/s$ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

ខ. សរសេរកន្សោមសមីការចលនារលកនៅត្រង់ចំណុច M

តាមសម្មតិកម្ម : $\lambda = 40\text{cm}$ ; $a = 15\text{cm}$ ; $x = 20$ និង $t = t$

តាមរូបមន្ត : $y_M = a\sin 2\pi\left(\frac{t}{T} - \frac{x}{\lambda}\right)$

$y_M = a\sin 2\pi\left(\frac{t}{1/8} - \frac{20}{40}\right)$ ឬ $y_M = a\sin 2\pi\left(8t - \frac{1}{2}\right)$

$y_M = a\sin\left(16\pi t - \frac{2\pi}{2}\right)$ ឬ $y_M = a\sin(16\pi t - \pi)$

$\boxed{y_M = -a\sin 16\pi t}$ ។

## មេរៀនសង្ខេប

- ការបញ្ជូនរញ្ជួយក្នុងមជ្ឈដ្ឋានដំណាលមួយហៅថា ចលនារលក ។
- រលកមានពីរប្រភេទគឺ រលកមេកានិច និងរលកអេឡិចត្រូម៉ាញេទិច ។
- រលកទទឹងគឺជាលំញ័រដែលកាត់កែងទៅនឹងទិសនៃដំណាល ។
- រលកបណ្តោយគឺជាលំញ័រដែលផ្លាស់ទីស្របនឹងទិសនៃដំណាល ។
- រលកមានលក្ខណៈចាំងផ្លាត ចាំងបែរ និងឌីប្រាក់ស្យុង នៅពេលណាដែលវាដាលទៅប៉ះនឹងរបាំង ។
- រលកចាំងផ្លាត ជារលកដែលកំពុងដាល កាលណាទៅប៉ះនឹងឧបសគ្គអ្វីមួយ អាចបកមកមជ្ឈដ្ឋានដើមវិញ ។
- ចំណាំងបែរនៃរលកបណ្តូរទិសដំណាល ។
- បំណត់រលកនៅចុងខាងរបាជាឌីប្រាក់ស្យុង ។
- រលកស៊ីនុយសូអ៊ីតជារលកមួយដែលគេធ្វើឱ្យមានប្រភពលំញ័រជាចលនាអាកម៉ូនិចងាយ និងមានរូបមន្ត : $x = A\sin(\omega t + \phi)$ ។

## សំណួរនិងលំហាត់

1. អ្វីទៅជារញ្ជួយ ? គេកំណត់ប្រភពរញ្ជួយបានដោយសារអ្វី ?
2. រលកមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
3. ក្នុងបណ្តាបាតុភូតខាងក្រោមនេះ តើបាតុភូតណាខ្លះមានទម្រង់ដំណាលជារលកបណ្តោយ ? ណាខ្លះជារលកទទឹង ? រលកទឹក រលកសំឡេង រលកវិទ្យុ រលករ៉ឺសរ និងរលកខ្សែ ។

4. ដើម្បីបង្កើតរលកខ្សែមួយ តើអ្នកត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ ? ចូរឱ្យឧទាហរណ៍បញ្ជាក់ប្រាប់ផង ។

5. ល្បឿនដំណាលនៃរញ្ជួយមានលក្ខណៈដូចម្ដេចខ្លះ ? កត្តាអ្វីខ្លះដែលមានឥទ្ធិពលទៅលើល្បឿនដំណាល ?

6. ក្មេងៗតែងយកកំប៉ុងពាសក្រដាសពីរមកភ្ជាប់ធ្វើជាទូរស័ព្ទដោយប្រើខ្សែអំបោះ ។ នៅពេលដែលធ្វើការទាក់ទងគ្នាវាស្ដាប់ពុំសូវឮច្បាស់ ។ បន្ទាប់មកវាយកខ្សែលាបជ័រទឹកទុកឱ្យស្ងួតនិងបិទក្រមួននៅខាងចុងខ្សែអំបោះជាប់ទៅនឹងក្រដាសភ្នាសនៅមាត់កំប៉ុង ធ្វើយ៉ាងនេះវាស្ដាប់បានឮច្បាស់ជាមុន ។ តើរលកដែលដាលនៅលើខ្សែអំបោះជារលកទទឹង ឬរលកបណ្ដោយ ? ចូរពន្យល់ ?

7. តើរលកមានលក្ខណៈសម្គាល់អ្វីខ្លះ ?

8. តើចំណាំងបែរនៃរលក និងចំណាំងផ្លាតនៃរលកកើតមានឡើងនៅពេលណា ?

9. តើរលកស៊ីនុយសូអ៊ីតមានចលនាដំណាលដូចម្ដេច ?

10. តើចលនារលកស៊ីនុយសូអ៊ីតអាចចាត់ទុកថាជាចលនាខួបដែរឬទេ ? ព្រោះអ្វី ?

## II. លំហាត់

1. ខ្សែមួយមានប្រវែង 5m និងមានម៉ាស 0.52kg ។ គេទាញវាឱ្យសន្ធឹងដោយកម្លាំង 46N ។ គណនា

   ក. ល្បឿនដំណាលនៃលំញ័រមួយនៅលើខ្សែ ។

   ខ. ប្រវែងរលកក្នុងករណីដែលគេដឹងថាលំញ័រមានប្រេកង់ 400Hz ។

2. ប្រភពលំញ័រមួយមានចលនា $y = 3\sin\left(125t + \frac{\pi}{3}\right)$ ។ ប្រភពនេះបញ្ជូនរលកដាលផុតខ្សែប្រវែង 25m ក្នុង 2.5s ។ តើល្បឿនដំណាល ខួប និងប្រវែងរបស់រលកមានតម្លៃប៉ុន្មាន ?

3. ខ្សែយឺតមួយមានចលនាទទឹងដោយមានប្រេកង់ 65Hz ។ ចំណុចដំបូងត្រង់ O ឈមនឹងផាសចុង M ឋិតនៅចម្ងាយ OM = 30cm ពី O ។ គណនាល្បឿននៃរលកខ្សែ ។

4. ប្រភពលំញ័រមួយមានសមីការ $y = a\sin\left(\omega t - \frac{\pi}{3}\right)$ និងមានចលនាត្រង់ប្រវែង 25m និងមានខួបស្មើនឹង 8s ។

   ក. រកអំព្លីទុត a និងប្រេកង់មុំ ω ដោយ t = 5s ។

   ខ. គណនាអេឡុងកាស្យុងនៃចំណុចមួយទៀតដែលឋិតនៅចម្ងាយ 20m ពីចំណុចមុននៅខណៈ t = 6s គេឱ្យជំហានរលក λ = 3.2m និងអំព្លីទុតថេរ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys



# រលកមេកានិច

- អ្នកបានរៀនរួចមកហើយនូវលក្ខណៈដូចគ្នាមួយចំនួននៃរលកទទឹង បណ្ដោយ។ តើអ្នកអាចរៀបរាប់បានដែរឬទេ?



## ថាមពលតាមរយៈរលកមេកានិច

- បើសិនជាអ្នកមិនទាន់បានលើកឡើងនូវលក្ខណៈនៃរលកមេកានិចដែលពាក់ព័ន្ធនឹងថាមពល តើអ្នកអាចពន្យល់បន្ថែមបានដែរឬទេ?







Slope = $\frac{\Delta y}{\Delta x}$
a
x
Wave motion
$\Delta y$
$\Delta x$
$P(x,t) = F_y(x,t)v_y(x,t) = -F\frac{\partial y(x,t)}{\partial x}\frac{\partial y(x,t)}{\partial t}$
$y(x,t) = A\cos(kx - \omega t)$
$P(x,t) = Fk\omega A^2\sin^2(kx - \omega t)$
$P(x,t) = \sqrt{\mu F}\,\omega^2A^2\sin^2(kx - \omega t)$
តើអនុភាពមធ្យមស្មើប៉ុន្មាន?
(b)
$F_x$
a
$F_y$


Slope = $\frac{\Delta y}{\Delta x}$
a
x
Wave motion
$\Delta y$
$\Delta x$
$P(x,t) = F_y(x,t)v_y(x,t) = -F\frac{\partial y(x,t)}{\partial x}\frac{\partial y(x,t)}{\partial t}$
$y(x,t) = A\cos(kx - \omega t)$
$P(x,t) = Fk\omega A^2\sin^2(kx - \omega t)$
$P(x,t) = \sqrt{\mu F}\,\omega^2A^2\sin^2(kx - \omega t)$
Wave power versus time t
at coordinate x = 0
P
$P_{max}$
$P_{av} = \frac{1}{2}P_{max}$
0
t
Period T




បើថាមពលមិនត្រូវបានបាត់បង់ពីចន្លោះផ្ទៃក្នុងនិងក្រៅនោះទេ តើទំនាក់ទំនងរវាង អាំងតង់ស៊ីតេនៃផ្ទៃទី ១ និង ទី២ គួរត្រូវបានកំណត់ដោយរបៀបណា?

## អាំងទែផេរ៉ង់ លក្ខខណ្ឌដែន និងតម្រួត

- តើអ្នកអាចពន្យល់បានទេថា ហេតុអ្វីខ្សែប្រែជាត្រង់ដោយគ្មានរញ្ជួយនៅពេលដែលរញ្ជួយទៅដល់ជញ្ជាំង?







## អាំងទែផេរ៉ង់ លក្ខខណ្ឌដែន និងតម្រួត

- តើហេតុអ្វីពេលចាំងផ្លាតមកវិញរញ្ជួយប្តូរទិសដៅនៃដំណាល និងបម្លាស់ទី?






## តើករណីនេះខុសពីមុនត្រង់ណា? ហេតុអ្វីទើបវាបែបនេះ?






តើអ្នកគិតថារូបនេះគេចង់បង្ហាញពីអ្វី?




oPhysics



oPhysics

តើអ្នកគិតថាគោលការណ៍នេះបង្ហាញពីសង្គតិភាពជាមួយនឹងសមីការរលកដែរឬទេ?

$$\frac{\partial^2 y(x,t)}{\partial x^2} = \frac{1}{v^2}\frac{\partial^2 y(x,t)}{\partial t^2}$$




# រលកជញ្ជ្រាំលើខ្សែ



# រលកជញ្ជ្រំលើខ្សែ









# រលកជញ្ជ្រំលើខ្សែ

តើអ្នកសង្កេតឃើញអ្វីខ្លះផ្អែកលើរូបនេះ?

តើរលកដែលដាលក្នុងទិសដៅផ្ទុយគ្នា មានលក្ខណៈដូចម្ដេចខ្លះ

$$y_1(x, t) = -A\cos(kx + \omega t)$$

$$y_2(x, t) = A\cos(kx - \omega t)$$

$$y(x, t) = y_1(x, t) + y_2(x, t) = (2A\sin kx)\sin \omega t$$

## រកទីតាំងនៃថ្នាំង

$$y(x, t) = (2A \sin kx) \sin \omega t$$

$$\sin kx = 0$$

$$x = 0, \frac{\pi}{k}, \frac{2\pi}{k}, \frac{3\pi}{k}, \ldots$$
$$= 0, \frac{\lambda}{2}, \frac{2\lambda}{2}, \frac{3\lambda}{2}, \ldots$$

## តើមានថាមពលត្រូវបានបញ្ជូនដោយរលកជញ្ជ្រាំ ◌ុឬទេ?

$$P(x, t) = F_y(x, t) v_y(x, t) = -F \frac{\partial y(x, t)}{\partial x} \frac{\partial y(x, t)}{\partial t}$$

ផ្អែកលើសមីការខាងលើ និងចម្លើយនៃអនុគមន៍រលកជញ្ជ្រាំ អ្នកនឹងរកឃើញថាអនុភាពមធ្យមគឺស្មើសូន្យ។ សូមសាកល្បងគណនា

# Normal Mode of a string

ប្រេកង់នៃរលកជញ្ជ្រំ ពេលខ្សែមិនផ្លាស់ទីនៅចុងសងខាង

ល្បឿនរលក

ប្រេកង់គ្រឹះ ពេល n=1

$$f_n = n\frac{v}{2L} = nf_1 \quad (n = 1, 2, 3, \ldots)$$

ប្រវែងខ្សែ




គេអាចប្រើម៉ូដទាំងនេះផ្គុំគ្នាដើម្បីបាននូវរលកបែបណាក៏បាន




# សង្ខេប




$$y(x,t) = A\cos\left[\omega\left(\frac{x}{v} - t\right)\right]$$

$$y(x,t) = A\cos 2\pi\left[\left(\frac{x}{\lambda} - \frac{t}{T}\right)\right]$$

$$y(x,t) = A\cos(kx - \omega t)$$

where $k = 2\pi/\lambda$ and $\omega = 2\pi f = vk$

$$\frac{\partial^2 y(x,t)}{\partial x^2} = \frac{1}{v^2}\frac{\partial^2 y(x,t)}{\partial t^2}$$

$$v = \sqrt{\frac{F}{\mu}} \text{ (waves on a string)}$$






$$f_n = n\frac{v}{2L} = nf_1 \ (n = 1, 2, 3, \ldots)$$

$$f_1 = \frac{1}{2L}\sqrt{\frac{F}{\mu}}$$

$$y(x,t) = A\cos(kx - \omega t)$$

$$P(x,t) = Fk\omega A^2 \sin^2(kx - \omega t)$$

$$P(x,t) = \sqrt{\mu F}\,\omega^2 A^2 \sin^2(kx - \omega t)$$

# លំហាត់វាយតម្លៃ




# មាតិកា

- រលកសូរ
- ល្បឿននៃរលកសូរ
- អាំងតង់ស៊ីតេសូរ

# សួរ៖ រលកស៊ីនុយសូអ៊ីត

$$y(x,t) = A\cos(kx - \omega t)$$

តើនេះគឺជារលកដាលស៊ីនុយសូអ៊ីតដាលក្នុងទិសដៅណា?



# រលកសួរ៖ រលកបណ្តោយ

- តើវាជាបំរែបំរួលចំនួនរូបអ្វីនៅត្រង់ចំណុចផ្សេងគ្នា ដែលនាំអោយកើតមានបាតុភូតរលកសួរ (ដូចរូប)?
- តើលំយោលនៃចំនួនរូបនេះជាប្រភេទលំយោលអ្វី?




រលកបណ្តោយ

# ការលឺសូរ

រលកសូរ → រំញ័រ → ក្រដាសត្រចៀក → ផ្នែកក្នុងត្រចៀក → កោសិកាសក់ → ខួរក្បាល




How Do We Hear Sound Through Ear? | Structure of Ear | Physics (byjus.com)



រលកសូរ




សូរដែលភាវៈរស់មួយចំនួនអាចស្តាប់លឺបាន

# រលកសូរ

- សូមស្តាប់សូរដែលប្រែប្រួលប្រេកង់ពីចន្លោះ 20 ទៅ 20,000 Hz




ក្រោម 20 Hz គេហៅថា សូរអាំងប្រា
លើស 20,000 Hz គេហៅថា សូរអ៊ុលត្រា

7




- Directionality of musical instruments (mw-acoustics.at)

8




# សូរះ រលកសូរក្នុងទម្រង់លំយោលសំពាធ

- ដុំម៉ាសភ្ជាប់ទៅនឹងរ៉ឺស័រវាយោលជៀបទៅនឹងទីតាំងលំនឹង (ពេលរ៉ឺស័រគ្មានកំរាញ) ចុះសំពាធនេះវិញវាយោលជៀបទៅនឹងអ្វី? តើប្រេកង់របស់វាដូចគ្នាទៅនឹងប្រេកង់នៃភាគល្អិតរបស់មជ្ឈដ្ឋានឬទេ?
- ជាគំនិតយើងចង់ផ្សារភ្ជាប់រវាងលំយោលនសំពាធទៅនឹងអនុគមន៍រលក









# សូរះ រលកសូរក្នុងទម្រង់លំយោលសំពាធ

- បម្រែបម្រួលមាឌនៃស៊ីឡាំងដែលទទួលរងរញ្ជួយគឺ

$$\Delta V = S(y_2 - y_1) = S[y(x+\Delta x,t) - y(x,t)]$$

- ប្រភាគនៃ $\Delta V$ ក្នុងលីមីត្រ $\Delta x \to 0$ គឺ

$$\frac{dV}{V} = \lim_{\Delta x \to 0} \frac{S(y_2 - y_1) = S[y(x+\Delta x,t) - y(x,t)]}{S\Delta x}$$

$$= \frac{\partial y(x,t)}{\partial x}$$




# សូរ៖ រលកសូរក្នុងទម្រង់លំយោលសំពាធ

- ទំនាក់ទំនងរវាងប្រភាគនៃបម្រែបម្រួលមាឌ និងលំយោលសំពាធគឺយើងត្រូវប្រើទំនាក់ទំនង Bulk Modulus

$$B = -\frac{p(x,t)}{dV/V} \text{ ឬ } p(x) = -B\frac{dV}{V}$$

- ដូចនេះទំនាក់ទំនងរវាង សំពាធនិងបំលាស់ទីភាគល្អិតនៃមជ្ឈដ្ឋានគឺ

$$p(x) = -B\frac{\partial y(x,t)}{\partial x}$$









- តើផាសរបស់ $y$ និង $p$ ខុសគ្នាប៉ុន្មានភាគ?
- តើទោះជាមិនបានបញ្ជាក់ក្នុងក្រាបតាងសម្ពាធ តើ $p_{max}$ ស្មើនឹងប៉ុន្មាន?


# សូរ៖ រលកសូរក្នុងទម្រង់លំយោលសំពាធ



- ទំនាក់ទំនងរវាងប្រភាគនៃបម្រែបម្រួលមាឌ និងលំយោលសំពាធគឺយើងត្រូវប្រើទំនាក់ទំនង Bulk Modulus

$$B = -\frac{p(x,t)}{dV/V} \text{ ឬ } p(x) = -B\frac{dV}{V}$$

- ដូចនេះទំនាក់ទំនងរវាង សំពាធនិងបំលាស់ទីភាគល្អិតនៃមជ្ឈដ្ឋានគឺ


$$p(x) = -B\frac{\partial y(x,t)}{\partial x} = BkA\sin(kx - \omega t)$$

# សោតវិញ្ញាណចំពោះរលកសូរ









# ល្បឿននៃរលកសូរ

$$v = \sqrt{\frac{\text{កម្លាំងរម្លឹកអោយភាគល្អិតត្រលប់ទៅរកទីតាំងដើម}}{\text{និចលភាពប្រឆាំងការត្រលប់ទៅទីតាំងដើម}}}$$

យើងអាចធ្វើការទាយថា ល្បឿនសូរដែលដាលក្នុងមជ្ឈដ្ឋានមួយស្មើនឹង

$$v = \sqrt{\frac{B}{\rho}}$$




# ល្បឿននៃរលកសូរះក្នុងសន្ទនីយ

1. ប្រើប្រាស់គោលគំនិតពាក់ព័ន្ធនឹងអាំពុលស្យុងដូចករណីរលកទទឹងដែរ
2. ត្រូវកំណត់ថាតើក្នុងរយ:ពេល $t$ រលកបណ្តោយដាលក្នុងមាឌសរុបប៉ុន្មាន ហើយក្នុងបរិមាណនៃមាឌនេះ តើប្រភាគនៃបម្រែបម្រួលមាឌដោយសារតែពីស្តុងស្មើនឹងប៉ុន្មាន នោះការកំណត់រកបម្រែបម្រួលបរិមាណចលនា និងអាំពុងស្យុងក្នុងរយ:ពេល $t$ និងអាចត្រូវបានកំណត់ក្នុងរយ:ពេល $t$
3. ប្រើទំនាក់ទំនងរបស់បំរែបំរួលបរិមាណចលនា និងអាំពុលស្យុងក្នុងរយ:ពេល $t$ អោយជាប់ពាក់ព័ន្ធនឹងល្បឿននៃដំណាលរលក






# ល្បឿននៃរលកសូរះក្នុងសន្ទនីយ

1. ប្រើប្រាស់គោលគំនិតពាក់ព័ន្ធនឹងអាំពុលស្យុងដូចករណីរលកទទឹងដែរ

$$I = Ft = \Delta pAt \quad (1)$$




# ល្បឿននៃរលកសូរៈក្នុងសន្ទនីយ

1. ប្រើប្រាស់គោលគំនិតពាក់ព័ន្ធនឹងអាំពុលស្យុង ដូចករណីរលកទទឹងដែរ

$$I = Ft = \Delta pAt \quad (1)$$

2. ត្រូវកំណត់ថាតើក្នុងរយៈពេល $t$ រលកបណ្តោយដាលក្នុងមាឌសរុបប៉ុន្មាន ហើយក្នុងបរិមាណនៃមាឌនេះ តើប្រភាគនៃបម្រែបម្រួលមាឌដោយសារតែពីស្តុងស្មើនឹងប៉ុន្មាន នោះការកំណត់រកបម្រែបម្រួលបរិមាណចលនា និងអាំពុងស្យុងក្នុងរយៈពេល $t$ និងអាចត្រូវបានកំណត់ក្នុងរយៈពេល $t$

- មាឌដែលដាលក្នុងរយៈពេល $t$ គឺ $V = Avt$ ហើយបម្រែបម្រួលមាឌដោយសារពីស្តុងគឺ $\Delta V = Av_y t$ ដូចនេះ

$$B = -\frac{\text{បម្រែបម្រួលសម្ពាធ}}{\text{ប្រភាគបម្រែបម្រួលមាឌ}} = -\frac{\Delta p}{\frac{Av_y t}{Avt}} \Rightarrow \Delta p = B\frac{v_y}{v}$$

$$(1): \quad I = \frac{Bv_y At}{v} \quad (2)$$






# ល្បឿននៃរលកសូរៈក្នុងសន្ទនីយ

$$B = -\frac{\text{បម្រែបម្រួលសម្ពាធ}}{\text{ប្រភាគបម្រែបម្រួលមាឌ}} = -\frac{\Delta p}{\frac{Av_y t}{Avt}} \Rightarrow \Delta p = B\frac{v_y}{v}$$

$$(1): \quad I = \frac{Bv_y At}{v} \quad (2)$$

3. ប្រើទំនាក់ទំនងរបស់បំរែបំរួលបរិមាណចលនា និងអាំពុលស្យុងក្នុងរយៈពេល $t$ អោយជាប់ពាក់ព័ន្ធនឹងល្បឿននៃដំណាល

- បរិមាណចលនាបណ្តោយ៖ $\Delta p_L = mv_y = (\rho vtA)v_y$ (3)
- តាម $I = \Delta p_L$ និង (2) &(3)៖

$$\frac{Bv_y At}{v} = (\rho vtA)v_y \Rightarrow v = \sqrt{\frac{B}{\rho}}$$




# ល្បឿននៃរលកសូរៈក្នុងអង្គធាតុរឹង និងឧស្ម័ន

- អង្គធាតុរឹង៖ $v = \sqrt{\frac{Y}{\rho}}$ ដែល $Y$ ជា Young's modulus នៃអង្គធាតុរឹងទ្រវែង ហើយ $\rho$ ជាម៉ាស មាឌនៃអង្គធាតុរឹង
- ឧស្ម័ន៖ $v = \sqrt{\frac{\gamma RT}{M}}$



# អាំងតង់ស៊ីតេសូរ

គ្រាមុនអ្នកបានសិក្សាទៅលើអនុភាពនៃរលកដាលលើខ្សែ

$$P(x,t) = F_y(x,t)v_y(x,t) = -F\frac{\partial y(x,t)}{\partial x}\frac{\partial y(x,t)}{\partial t}$$
$$= \sqrt{\mu F}\omega^2 A^2 \sin^2(kx - \omega t)$$

ពេលនេះយើងនឹងធ្វើការសិក្សាពីអនុភាពនៃរលកសូរដាលក្នុងសន្ទនីយក្នុងមួយខ្នាតផ្ទៃ

$$I(x,t) = p(x,t)v_y(x,t)$$
$$= [BkA\sin(kx - \omega t)][\omega A\sin(kx - \omega t)]$$
$$= B\omega kA^2\sin^2(kx - \omega t) = \sqrt{\rho B}\omega^2 A^2 \sin^2(kx - \omega t)$$

តើអាំងតង់ស៊ីតេមធ្យមស្មើប៉ុន្មាន?




Animations of Instantaneous Intensity (psu.edu)

# អាំងតង់ស៊ីតេសូរ

ពេលនេះយើងនឹងធ្វើការសិក្សាពីអនុភាពនៃរលកសូរដាលក្នុងសន្ទនីយក្នុងមួយខ្នាតផ្ទៃ

$$I(x,t) = p(x,t)v_y(x,t)$$
$$= [BkA\sin(kx-\omega t)][\omega A\sin(kx-\omega t)]$$
$$= B\omega kA^2\sin^2(kx-\omega t) = \sqrt{\rho B}\omega^2A^2\sin^2(kx-\omega t)$$

តើអាំងតង់ស៊ីតេមធ្យមស្មើប៉ុន្មាន?

- ប្រើប្រាស់ទំនាក់ទំនងសម្ពាធអាំព្លីទុត៖ $p_{max} = BKA$
- និងល្បឿនផាស, $v = \omega/k$ គេបានអាំងតង់ស៊ីតេមធ្យមជាអនុគមន៍សម្ពាធអាំព្លីទុត

$$I(x,t) = \frac{\omega p_{max}^2}{2Bk} = \frac{vp_{max}^2}{2B} = \frac{p_{max}^2}{2\rho v} = \frac{p_{max}^2}{2\sqrt{\rho B}}$$




Animations of Instantaneous Intensity (psu.edu)



# កម្រិតអាំងតង់ស៊ីតេសូរៈ មាត្រដ្ឋានដេស៊ីបែល

$$\beta = (10\text{ dB})\log\frac{I}{I_0}$$

$\beta$: កម្រិតអាំងតង់ស៊ីតេសូរ

$I$: អាំងតង់ស៊ីតេសូរ

$I_0$: អាំងតង់ស៊ីតេយោង ($10^{-12}\text{W/m}^2$)

log: គោលដប់



# កម្រិតអាំងតង់ស៊ីតេសូរ៖ មាត្រដ្ឋានដេស៊ីប៊ែល

$$\beta = (10\ \text{dB}) \log \frac{I}{I_0}$$

$\beta$: កម្រិតអាំងតង់ស៊ីតេសូរ

$I$: អាំងតង់ស៊ីតេសូរ

$I_0$: អាំងតង់ស៊ីតេយោង ($10^{-12}\text{W/m}^2$)

log: គោលដប់

| Source or Description of Sound | Sound Intensity Level, $\beta$ (dB) | Intensity, $I$ (W/m$^2$) |
|---|---|---|
| Military jet aircraft 30 m away | 140 | $10^2$ |
| Threshold of pain | 120 | 1 |
| Riveter | 95 | $3.2 \times 10^{-3}$ |
| Elevated train | 90 | $10^{-3}$ |
| Busy street traffic | 70 | $10^{-5}$ |
| Ordinary conversation | 65 | $3.2 \times 10^{-6}$ |
| Quiet automobile | 50 | $10^{-7}$ |
| Quiet radio in home | 40 | $10^{-8}$ |
| Average whisper | 20 | $10^{-10}$ |
| Rustle of leaves | 10 | $10^{-11}$ |
| Threshold of hearing at 1000 Hz | 0 | $10^{-12}$ |

ហេតុអ្វីចាំបាច់គិតយកមាត្រដ្ឋានដេស៊ីប៊ែល?

23

# អាំងតង់ស៊ីតេសូរ




24

# សូរ




សម្លេងនៃប្រេកង់មួយបង្កើតបានជារលកជញ្ជ្រាំ

ថ្នាំងសម្ពាធគឺជាពោះបម្លាស់ទី ហើយពោះសម្ពាធជាថ្នាំងបម្លាស់ទី។ ចូរពិភាក្សាទៅលើប្រយោគនេះ។




# កិច្ចពិភាក្សាក្រុមៈ រលកសូរជញ្ជាំង




**១.** ឧបករណ៍បំពងសម្លេងមួយបានបញ្ចេញរលកសូរស្ទូរដែលមានជំហានរលក $\lambda$ ដែលមានទិសដៅទៅរកជញ្ជាំងមួយ (ដូចរូប)។ តើនៅចម្ងាយប៉ុន្មានពីជញ្ជាំងដែលអ្នកមិនលឺសូរសម្លេងទាល់តែសោះ?

# ឧបករណ៍បំពងសម្លេងប្រើខ្យល់ (Wind Instrument)




# បំពង់ចំហរ (Open Pipe)



# បំពង់បិទ (Stopped Pipe)




# កិច្ចការក្រុម៖

២. រលកសូរដែលមានល្បឿន 344 m/s ហើយបំពង់បិទមួយមានហ្វ្រេកង់គ្រឹះ 220 Hz ។ (ក) តើបំពង់នេះមានប្រវែងប៉ុន្មាន? (ខ) អាម៉ូនិចទី២ នៃបំពង់នេះ មានជំហ៊ានរលកដូចទៅនឹងអាម៉ូនិចទី៣នៃបំពង់ចំហរ។ តើបំពង់នេះមាន ប្រវែងប៉ុន្មាន? ចូរធ្វើការប្រៀបធៀបហ្វ្រេកង់គ្រឹះនៃប្រភេទបំពង់ទាំងពីរ។

# បំពង់ចំហរនិងបិទនៃឧបករណ៍តន្ត្រី

៣. តើអ្នកគិតថាឧបករណ៍តន្ត្រីក្នុងទម្រង់ជាបំពង់បិទឬចំហរទាំងនេះប្រែប្រួលសំលេងទៅតាមសីតុណ្ហភាពនៃមជ្ឈដ្ឋានឬទេ? ចូរវិភាគ។





# កិច្ចការក្រុម

៤. ប្រសិនបើអ្នកផ្លុំបំពង់មួយដែលមានខ្យល់នៅខាងក្នុង អ្នកនឹងបង្កើតបានសូរសំលេងមួយ។ បើសិនជាអ្នកផ្លុំបំពង់ដដែលតែមានឧស្ម័នអេលីយ៉ូមនៅខាងក្នុងដោយសម្ពាធនិងលក្ខខណ្ឌបំពង់ដែលមានខ្យល់នៅខាងក្នុង តើបំពង់ដែលមានអេលីយ៉ូមនឹងបង្កើតបាននូវ (ក) សំលេងតុងដូចគ្នា? (ខ) តុងខ្ពស់ជាងមុន? (គ) តុងទាបជាងមុន?




Two speakers
emit waves in phase.
Amplifier
$d_2 + \frac{\lambda}{2}$
$d_2$
$d_1$
$d_1$
$Q$
$P$
The path length from the speakers is the same; sounds from the two speakers arrive at $P$ in phase.
The path length from the speakers differs by $\frac{\lambda}{2}$; sounds from the two speakers arrive at $Q$ out of phase by $\frac{1}{2}$ cycle.

# អាំងទែផេរ៉ង់នៃរលក




# កិច្ចការក្រុម៖ អាំងទែផេរ៉ង

៥. ធុងបាសពីរបង្កើតសូរសំលេងជារលកស៊ីនុយសូអ៊ីតដែលមានផាសដូចគ្នាចេញពីអំភ្លីតែមួយ។

(ក) តើប្រេកង់ស្មើប៉ុន្មានខ្លះដើម្បីបង្កើតបាននូវអាំងទែផេរ៉ង់សង់ត្រង់ទីតាំង $P$ ?

(ខ) តើប្រេកង់ស្មើប៉ុន្មានខ្លះនៃអាំងទែផេរ៉ង់បំផ្លាញត្រង់ទីតាំង $P$ ?



# Doppler Effect: អ្នកស្តាប់ផ្លាស់ទី ប្រភពនៅស្ងៀម




# Doppler Effect: អ្នកស្តាប់និង ប្រភពផ្លាស់ទី



# ឧទាហរណ៍៖ កិច្ចការក្រុម

៦. សារ៉ែនឡានប៉ូលីសមួយបានបញ្ចេញរលកស៊ីនុយសូអ៊ីតដែលមានប្រេកង់ $f_s = 300\ \text{Hz}$ ។ ល្បឿននៃសូរស្មើនឹង 340 m/s ហើយមជ្ឈដ្ឋានខ្យល់នៅស្ងៀម។
(ក) រកជំហានរលកនៃរលកបើឡានប៉ូលីសនៅស្ងៀម។
(ខ) រកជំហ៊ានរលកនៃសូរដែលនៅពីក្រោយនិងមុខឡានប៉ូលីសដែលកំពុងផ្លាស់ទីដោយល្បឿន 30 m/s







# ឧទាហរណ៍៖ កិច្ចការក្រុម

៧. បើសិនជាអ្នកឈរនៅស្ងៀមហើយប្រភពសូរនៅក្នុងឧទាហរណ៍មុនផ្លាស់ទីចាកចេញពីអ្នកដោយល្បឿន 30 m/s តើអ្នកលឺសូរប្រេកង់ប៉ុន្មាន?

# ឧទាហរណ៍៖ កិច្ចការក្រុម

៨. បើសិនជាឡាននៅក្នុងឧទាហរណ៍មុននៅស្ងៀម ហើយអ្នកស្ដាប់ផ្លាស់ទីចាកចេញពីឡានដោយល្បឿន 30 m/s តើប្រេកង់ស្មើនឹងប៉ុន្មាន?







# ឧទាហរណ៍៖ កិច្ចការក្រុម

៩. ឡានសារ៉ែនផ្លាស់ទីចេញពីអ្នកស្ដាប់ដោយល្បឿន 45 m/s ធៀបទៅនឹងខ្យល់ ហើយអ្នកស្ដាប់ផ្លាស់ទីទៅកាន់ឡានដោយល្បឿន 15 m/s ធៀបទៅនឹងខ្យល់ តើអ្នកស្ដាប់លឺប្រេកង់ប៉ុន្មាន?

# ឧទាហរណ៍៖ កិច្ចការក្រុម

១០. ឡានប៉ូលិសកំពុងផ្លាស់ទីសំដៅទៅរកអាគារមួយដោយល្បឿន 30 m/s ។ តើអ្នកបើកបរស្តាប់លឺប្រេកង់ស្មើនឹងប៉ុន្មានចេញពីសូរដែលចាំងផ្លាតពីជញ្ជាំងនៃអាគារនោះ?




# តេស្ត

# អុបទិចធរណីមាត្រ

## មាតិកា

- កញ្ចក់ប្លង់
- កញ្ចក់ស្វ៊ែប៉ោងនិងស្វ៊ែផត
- រូបភាពបង្កើតដោយផ្ទៃកោងនៅចន្លោះមជ្ឈដ្ឋាន២
- ប្រភេទនិងលក្ខណៈឡង់ទី






# សេចក្តីផ្តើម

## ចំណុចវត្ថុ

បាច់ពន្លឺបន្សាយពីចំណុច $P$ ទៅគ្រប់ទិសក្នុងមជ្ឈដ្ឋានស្មើសាច់តាមខ្សែត្រង់។



## កញ្ចក់ប្លង់




## កញ្ចក់ប្លង់






# ផ្ទៃប្លង់ចាំងបែរ




## កញ្ចក់ប្លង់៖ វិធាននៃការកំណត់សញ្ញា






# កញ្ចក់ប្លង់៖ វិធាននៃការកំណត់សញ្ញា

- សញ្ញានៃចម្ងាយវត្ថុ៖ នៅពេលដែលវត្ថុស្ថិតនៅខាងដូចគ្នានឹងបាច់បន្ទឺចូល (ធៀបនឹងផ្ទៃចាំងផ្លាតឬបែរ) ចម្ងាយវត្ថុគឺវិជ្ជមាន។ បើមិនដូច្នោះទេគឺ អវិជ្ជមាន
- សញ្ញានៃចម្ងាយរូបភាព៖ នៅពេលដែលរូបភាពស្ថិតនៅខាងដូចគ្នានឹងបាច់ពន្លឺចេញ (ធៀបនឹងផ្ទៃចាំងផ្លាតឬបែរ) ចម្ងាយរូបភាពគឺវិជ្ជមាន។ បើមិនដូច្នោះទេគឺអវិជ្ជមាន
- សញ្ញានៃកាំកំណោងរបស់ផ្ទៃស្វ៊ែ៖ នៅពេលដែលផ្ចិតរបស់ស្វ៊ែស្ថិតនៅខាងតែមួយនៃបាច់ពន្លឺចេញ (ធៀបនឹងផ្ទៃចាំងផ្លាតឬបែរ) កាំកំណោងគឺ វិជ្ជមាន។ បើមិនដូច្នោះទេ គឺអវិជ្ជមាន




# វត្ថុលាតសន្ទឹង៖ កញ្ចក់ប្លង់

# វត្ថុលាតសន្ទឹង៖ កញ្ចក់ប្លង់










## វត្ថុលាតសន្ទឹង៖ កញ្ចក់ប្លង់

១. តើអ្នកគិតថារូបនេះមានលក្ខណៈបែបណា? តាមរូបវិធានដៃស្តាំដែលអ្នកបានឃើញ និងរូបមួយនេះតើអ្នកអាចទាញសេចក្តីសន្និដ្ឋានបានដូចម្តេច?

# ចំណាំងផ្លាតនៃកញ្ចក់ប្លង់ពីរឬច្រើន











## សំណួរ

២. បើអ្នកដើរសំដៅទៅរកកញ្ចក់ប្លង់ដោយល្បឿន $v$ តើរូបភាពរបស់អ្នកដើរដោយល្បឿនប៉ុន្មានមកកាន់អ្នកឬធៀបជាមួយអ្នក?




# ចំណាំងផ្លាតនៃផ្ទៃស្វ៊ែ ៖ កញ្ចក់ស្វ៊ែផត

## វិធាននៃការកំណត់សញ្ញា

សញ្ញានៃកាំកំណោងរបស់ផ្ទៃស្វ៊ែ៖ នៅពេលដែលផ្ចិតរបស់ស្វ៊ែស្ថិតនៅខាងដូចគ្នានឹងបាច់ពន្លឺចេញ (ធៀបនឹងផ្ទៃចាំងផ្លាតឬបែរ) កាំកំណោងគឺ វិជ្ជមាន។ បើមិនដូច្នោះទេ គឺអវិជ្ជមាន






# ចំណុចកំនុំនិង ប្រវែងកំនុំ




# វត្ថុលាតសន្ធឹង៖ កញ្ចក់ស្វ៊ែផត




# វត្ថុលាតសន្ទឹង៖ កញ្ចក់ស្វ៊ែផត




ផ្នែកមួយនៃកញ្ចក់កោង




# វត្ថុលាតសន្ទឹង៖ កញ្ចក់ស្វ៊ែផត

# ឧទាហរណ៍ទី១

៣. រក $R, m$ និង $h'$




# កញ្ចក់ស្វ៊ែប៉ោង







៤. ចូរស្រាយបញ្ជាក់ថាទំនាក់ទំនងវត្ថុនិងរូបភាពគឺដូចគ្នាទៅនឹងកញ្ចក់ស្វ៊ែផតតើយើងកំណត់យកវិធានសញ្ញានៃចម្ងាយវត្ថុ រូបភាពនិងកាំកំណោង។




## កញ្ចក់ស្វ៊ែប៉ោង

៥. ដោយផ្អែកទៅលើទំនាក់ទំនងខាងលើចូរបង្ហាញថាសម្រាប់កាំពន្លឺចាំងប៉ះ(ដូចរូប) $s = \infty$ ហើយ $s' = \infty$

## ៦. ចូររក $s', m$ និង $y'$



# វិធីសាស្ត្រគូរក្រាបសម្រាប់កញ្ចក់




## ឧទាហរណ៍

៦. ផ្អែកទៅលើរូបទាំងបួន នេះ ចូររៀបរាប់ធ្វើសេចក្ដីសន្និដ្ឋានពីលក្ខណៈរបស់រូបភាពដោយផ្អែកទៅលើទីតាំងរបស់វត្ថុ។






ចំណុចរូបភាពបង្កើតដោយផ្ទៃស្វ៊ែនៅចន្លោះមជ្ឈដ្ឋាន២

៧. ហេតុអ្វីយើងប្រើផ្ទៃប៉ោងដើម្បីស្រាយរូបមន្តទូទៅ?

# រូបភាពលាតសន្ធឹងបង្កើតដោយផ្ទៃស្វ៊ែនៅចន្លោះមជ្ឈដ្ឋាន២




៨. ចូរបង្ហាញថា $m \equiv \frac{y'}{y} = -\frac{n_a s'}{n_b s}$

៩. រក $s'$ និង $m$




## ឧទាហរណ៍៖ ជម្រៅទំនងអាងទឹក

១០. រក $s'$ បើ $s = 2.00$ m



# ឡង់ទីស្តើងៈលក្ខណៈ




# រូបភាពលាតសន្ទឹងបង្កើតដោយឡង់ទីបង្រួម




oPhysics

១១. ចូរបង្ហាញថា $\frac{1}{s}+\frac{1}{s'}=\frac{1}{f}$ ។ ដោយប្រើប្រាស់ Simulation តើបាតុភូតនៃបាច់ពន្លឺចាំងបែរពេលវត្ថុស្ថិតត្រង់ទីតាំងកំនុំមានសង្គតិភាពជាមួយនឹងរូបមន្តខាងលើឬទេ?

# រូបភាពបង្កើតដោយឡង់ទីបង្រួម




យើងនឹងស្វែងយល់ពីរូបនេះ បន្ទាប់ពីបានពិភាក្សាលើ កិច្ចការទី ១១ សិន។

## ឡង់ទីពង្រីក




កាំកំណោងនៃឡង់ទីពង្រីកគឺ អវិជ្ជមាន



# ប្រភេទឡង់ទី




# រូបភាពបង្កើតដោយមេទីសពង្រីក






១២. ចូររក $f$ បើកាំកំណោងនៃផ្ទៃឡង់ទីទាំងសងខាងស្មើនឹង 10 cm។

# វិធីសាស្ត្រ

Figure 34.36 The graphical method of locating an image formed by a thin lens. The colors of the rays are for identification only; they do not refer to specific colors of light. (Compare Fig. 34.19 for spherical mirrors.)



# ឧទហរណ៍




## ឧទាហរណ៍៖ ឡង់ទីពង្រីក

១៣. ចូរគណនាដើម្បីបង្ហាញថាតម្លៃលេខដែលបានបង្ហាញដូចរូបគឺត្រឹមត្រូវឬមិនត្រឹមត្រូវ។



# ឧទាហរណ៍

១៤. វត្ថុមាន ប្រវែង 8 cm។ រកទីតាំង ប្រវែង និងទិសដៅ របស់រូបភាពបង្កើតដោយឡង់ទីទាំងពីរ។



**កិច្ចការត្រូវអនុវត្តដើម្បីសម្រេចលទ្ធផលសិក្សារំពឹងទុក៖**

- ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖
    - ១. កិច្ចការទី ១៖...........
    - ២. កិច្ចការទី ២៖...........
    - ៣. កិច្ចការទី ៣៖...........
    - ៤. កិច្ចការទី ៤៖...........
    - ៥. កិច្ចការទី ៥៖...........